**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០១៤

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 05-May-2014, 16:07
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

**បណ្ដឹងសាទុក្ខឆ្លាមៗរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្ដីសម្រេច**
**លើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២**
**និងលើការកំណត់វិសាលភាពនៃសំណុំរឿង ០០២/០២**

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**
មេធាវី គង់ សំអុន
មេធាវី Anta GUISSÉ
មេធាវី Arthur VERCKEN

ដាក់ជូន៖

**អង្គជំនុំជម្រះតុលាការកំពូល៖**
ចៅក្រម គង់ ស្រីម
ចៅក្រម Agnieszka KLONOWIECKA-MILART
ចៅក្រម **សោម សិរីវឌ្ឍ**

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Soumeya MEDJEBEUR
លោក Pierre TOUCHE
កញ្ញា អ៊ួច ស្រីផាត

ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្ដីលោក នួន ជា**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

១. នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង ០០២ ដែលខ្លួនបានសម្រេចថានឹងពិនិត្យមើល ក្នុងក្របខ័ណ្ឌនៃការជម្រះក្តីជាវគ្គៗដាច់ដោយឡែកពីគ្នា ដែលវគ្គនីមួយៗត្រូវដាក់បញ្ចូលអង្គហេតុខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងចេញសាលក្រមមួយ នៅពេលបញ្ចប់ការជំនុំជម្រះក្តី[1]។

២. នៅថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធីនេះ ដោយបានកត់សម្គាល់ឃើញកំហុស និងព្យសនកម្មជាច្រើន ដែលភាគីបានទទួលរង បណ្តាលមកពីការបំបែកនេះ[2]។

៣. នៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានប្រកាសក្នុងសវនាការថា ខ្លួនបានសម្រេចបំបែកបទចោទជាថ្មីម្តងទៀត ហើយនឹងចេញសំអាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួនជាលាយលក្ខណ៍អក្សរ នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣[3]។

៤. នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចលើការបំបែកកិច្ចដំណើការនីតិវិធីសាជាថ្មីនេះ ដោយផ្តល់តែសេចក្តីសង្ខេបសំអាងហេតុនៃសេចក្តីសម្រេចខ្លួនរបស់ខ្លួនប៉ុណ្ណោះ។ នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ អង្គជំនុំជម្រះតុលាការកំពូល បានចេញសំអាង

---

[1] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ **E124**។

[2] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីវិសាលភាពនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E163/5/1/13** (“សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E163/5/1/13**”)។

[3] ប្រតិចារឹកសវនាការ ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **E1/176.1** ទំព័រ ២ បន្ទាត់ ១៧ ដល់ទំព័រ ៤ បន្ទាត់ ១២ (ចន្លោះម៉ោង [09.05.38] ដល់ម៉ោង [09.11.05]), សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E284**។

ហេតុពិស្តារ[4]។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល មិនបានប្រកាសមោឃភាពការបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មីនេះក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូល បានកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសជាច្រើន ហើយបានប្រើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការកែប្រែសេចក្តីសម្រេច។

៥. នៅថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ខណៈពេលកំពុងតាក់តែងសាលក្រមលើការជំនុំជម្រះក្តីវគ្គមួយ (សំណុំរឿង ០០២/០១) អង្គជំនុំជម្រះសាលាដំបូង បានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងបានកំណត់វិសាលភាពនៃការជំនុំជម្រះក្តីវគ្គពីរ (សំណុំរឿង ០០២/០២) ដោយកម្រិតជាថ្មីម្តងទៀតមកត្រឹមការពិនិត្យអង្គហេតុនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[5]។

៦. ថ្ងៃនេះ ស្របតាមវិធាន ១០៤ នៃវិធានផ្ទៃក្នុង មេធាវីការពារក្តីលោក ខៀវ សំផន ("ម្ចាស់បណ្តឹងសាទុក្ខ") សូមប្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូង ("សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ") ដែលត្រូវធ្វើមោឃភាព ពីព្រោះសេចក្តីសម្រេចនេះមានកំហុសអង្គច្បាប់ និងកំហុសស្តែងចេញពីការប្រើឆន្ទានុសិទ្ធិ។

## I. ភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ

៧. យោងតាមវិធាន ១០៤(៤)(ក) នៃវិធានផ្ទៃក្នុង និងយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល សេចក្តីសម្រេចនេះ បើកផ្លូវឲ្យប្តឹងសាទុក្ខបានភ្លាមៗ។

---

[4] សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ - សេចក្តីសង្ខេបនៃសំអាងហេតុ ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១៣ ឯកសារ **E284/4/7**, សេចក្តីសម្រេចសលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែក កិច្ចដំណើរការនីតិវិធីនៃសំណុំរឿង០០២ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ឯកសារ **E284/4/8** ("សេចក្តីសម្រេចលើកទីពីរ របស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8**")។

[5] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **E301/9/1** ("សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ")។

៨. អង្គជំនុំជម្រះតុលាការកំពូល បានបកស្រាយវិធាន ១០៤(៤)(ក) ថា *"គ្រប់ដណ្តាប់លើរាល់សេចក្តីសម្រេចផ្អាកការចោទប្រកាន់ ដែលមិនបានសន្យាច្បាស់លាស់ថានឹងចាប់ផ្តើមកិច្ចដំណើរការនីតិវិធីឡើងវិញ និងដែលរារាំងដល់ការប្រកាសសេចក្តីសាលក្រមលើអង្គសេចក្តី"*[6]។

៩. ដូចគ្នានឹងសេចក្តីសម្រេចបំបែកកិច្ចដំណើការនីតិវិធី ដែលអង្គជំនុំជម្រះសាលាដំបូងបានចេញពីមុន និងដែលអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថាអាចប្តឹងសាទុក្ខបានភ្លាមៗ សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ មានអានុភាពផ្អាករាល់ការចោទប្រកាន់ទាំងអស់ ដែលស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះក្តី ដែលអង្គជំនុំជម្រះសាលាដំបូងបានកំណត់។ ដូចជាសេចក្តីសម្រេចមុនៗដែរ ការផ្អាកថ្មីនេះ មិនផ្តល់ការសន្យាច្បាស់លាស់គ្រប់គ្រាន់ថានឹងចាប់ផ្តើមឡើងវិញ ដែលអាចឈានទៅដល់ការចេញសាលក្រមលើអង្គសេចក្តីមួយ។

១០. ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ដោយខ្លួនឯងផ្ទាល់ថា ការបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី *"មិនរាប់បញ្ចូលអង្គហេតុ បទចោទ និងទីតាំងឧក្រិដ្ឋកម្មមួយចំនួន ក្នុងសំណុំរឿង ០០២/០២"*[7]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះសាលាដំបូង មិនបានផ្តល់ព័ត៌មានអំពីជោគវាសនានៃអង្គហេតុ បទចោទ និងទីតាំងឧក្រិដ្ឋកម្ម ដែលនៅសេសសល់នោះទេ។ អង្គជំនុំជម្រះសាលាដំបូង គ្រាន់តែលើកឡើងអំពីលទ្ធភាព (ដែលអង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញ) ក្នុងការ *"ដកចេញបទចោទមួយចំនួនចេញពីការជំនុំជម្រះ"* ដោយអះអាងថាខ្លួនមិនទាន់បានទទួលសំណើណាមួយក្នុងន័យនេះ ពីសហព្រះរាជអាជ្ញានៅឡើយ[8]។ ក្នុងផ្នែកសម្រេចសេចក្តីនៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង *"ប្រកាសមិនពិចារណាសម្រេចនៅពេលនេះចំពោះបទចោទនានាដែលមិនបានដាក់បញ្ចូលនៅក្នុងសំណុំរឿង ០០២/០២ ហើយអង្គជំនុំជម្រះនឹងលើកយកបញ្ហានេះមកដោះស្រាយ ក្នុងពេលវេលាសមស្រប"*[9]។

---

[6] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ២១។

[7] សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ កថាខណ្ឌ ៤៥។

[8] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៤៥។

[9] សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ ផ្នែកសម្រេចសេចក្តី កថាខណ្ឌមុនចុងក្រោយ។

១១. ផ្ទុយទៅវិញ អង្គជំនុំជម្រះតុលាការកំពូល បានសន្និដ្ឋានពីរដងរួចមកហើយថា នៅពេលបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុស ដោយសារមិនបានផ្តល់ *"ផែនការច្បាស់លាស់"* ពាក់ព័ន្ធនឹងការជំនុំជម្រះក្តីវគ្គបន្តបន្ទាប់ ក្រោយពីការជំនុំជម្រះវគ្គមួយរួច ដែលត្រូវបានកំណត់វិសាលភាពដោយការបំបែកកិច្ចដំណើរការនីតិវិធី[10]។ គួរកត់សម្គាល់ផងដែរថា អង្គជំនុំជម្រះសាលាដំបូង កំពុងប្រព្រឹត្តកំហុសដដែលនេះជាថ្មីម្តងទៀត។

១២. លើសពីនេះទៅទៀត កាលៈទេសៈផ្សេងទៀតដែលកើតមានឡើង ក្នុងពេលបំបែកកិច្ចដំណើរការនីតិវិធីលើកមុនៗ នៅតែមានសុពលភាពដដែល[11]។ ជាក់ស្តែង នៅក្នុងសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង តែងតែលើកយកភាពឆាប់រហ័សនៃកិច្ចដំណើរការនីតិវិធីមកធ្វើជាសំអាង ហើយលើកឡើងដដែលៗនូវកង្វល់ចម្បងរបស់ខ្លួន ក្នុងការធ្វើយ៉ាងណាឲ្យអាច *"ចេញសាលក្រមមួយលើបទចោទមួយចំនួននៃដីកាដំណោះស្រាយ ក្នុងពេលជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ នៅរស់រានមានជីវិត"*[12]។

១៣. អាស្រ័យហេតុដូចបានរៀបរាប់ខាងលើនេះ សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ គឺជាការផ្អាកកិច្ចដំណើរការនីតិវិធីលើបទចោទទាំងអស់ ដែលស្ថិតនៅក្រៅវិសាលភាពសំណុំរឿង ០០២/០២។ ក្នុងកាលៈទេសៈបច្ចុប្បន្ននេះ ការផ្អាកនេះមិនមានការសន្យាច្បាស់លាស់គ្រប់គ្រាន់ថានឹងចាប់ផ្តើមឡើងវិញ ដែលអាចឈានទៅដល់ការចេញសាលក្រមលើអង្គសេចក្តីមួយឡើយ។

១៤. ដូច្នេះ សេចក្តីសម្រេចនេះ បើកផ្លូវឲ្យប្តឹងសាទុក្ខបានភ្លាមៗ ហើយត្រូវធ្វើមោឃភាព ពីព្រោះអង្គជំនុំជម្រះសាលាដំបូងប្រព្រឹត្តកំហុស ដែលធ្វើឲ្យសេចក្តីសម្រេចរបស់ខ្លួនគ្មានសុពលភាព ហើយបង្កឲ្យមានព្យសនកម្មទៅលើម្ចាស់បណ្តឹងសាទុក្ខ។

---

[10] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ២៣ និងកថាខណ្ឌ ២៤។

[11] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ២៣ និងកថាខណ្ឌ ២៥។

[12] សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣ កថាខណ្ឌ ២៣ កថាខណ្ឌ ២៧ កថាខណ្ឌ ២៨។

## II. ការបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី មិនមែនផ្អែកលើផលប្រយោជន៍យុត្តិធម៌

១៥. នៅពេលសម្រេចបំបែកបទចោទសាជាថ្មី ក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូង មិនបានគោរពច្បាប់ជាធរមាន តាមការប្រកាសរបស់អង្គជំនុំជម្រះតុលាការកំពូល នោះទេ។ ដូច្នេះ ទង្វើបែបនេះ បង្ហាញថាអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តកំហុសអង្គច្បាប់ជាច្រើន និងកំហុសស្តែងចេញពីការប្រើឆន្ទានុសិទ្ធិ ដែលបង្កឲ្យមានព្យសនកម្មដល់ម្ចាស់បណ្តឹងសាទុក្ខ។

១៦. ការអានផ្នែកច្បាប់ជាធរមាននៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ[13] ស្តែងឲ្យឃើញថា អង្គជំនុំជម្រះសាលាដំបូង មិនអើពើលើបទប្បញ្ញត្តិទូទៅ ដែលទាមទារយ៉ាងច្បាស់ដោយអង្គជំនុំជម្រះតុលាការកំពូល ហើយបន្ទាប់មកទៀត ខ្លួនបំភ្លេចចោលបទប្បញ្ញត្តិទូទៅនេះ ក្នុងផ្នែកសំអាងហេតុនៃសេចក្តីសម្រេចរបស់ខ្លួនស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី។

១៧. ជាក់ស្តែង អង្គជំនុំជម្រះតុលាការកំពូល បានរំឭករួចមកហើយថា *"សេចក្តីសម្រេចលើការបំបែកនេះ គឺជាករណីពិសេសចំពោះការជំនុំជម្រះរួមបញ្ចូលគ្នា"*[14]។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានរំឭកផងដែរថា ឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវមានព្រំដែនកម្រិត ជាពិសេស ក្នុងសំណុំរឿងធំធេង និងស្មុគស្មាញ ដូចសំណុំរឿង ០០២ នេះ ដែលការបំបែកមានផលប៉ះពាល់យ៉ាងធំធេង និងខ្លាំងក្លាដោយជៀសពុំរួច ទៅលើភាគី[15]។

១៨. លើសពីនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូល បានផ្តល់សេចក្តីចង្អុលបង្ហាញច្បាស់លាស់ ស្តីពីរបៀបបកស្រាយល័ក្ខខ័ណ្ឌតម្រូវថាការបំបែកបទចោទ ត្រូវតែផ្អែកលើផលប្រយោជន៍យុត្តិធម៌៖ *"ទោះបីជាឆន្ទានុសិទ្ធិដែលបានផ្តល់ឲ្យអង្គជំនុំជម្រះសាលាដំបូង ក្នុងការបំបែកកិច្ចដំណើរការនីតិវិធី មានភាពទូលំទូលាយយ៉ាងណាក៏ដោយ ក៏ផលប្រយោជន៍យុត្តិធម៌ ចាំបាច់តម្រូវឲ្យបង្ហាញ*

---

[13] សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ កថាខណ្ឌ ១៣ និងកថាខណ្ឌ ១៤។

[14] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E163/5/1/13** កថាខណ្ឌ ៣៣។

[15] សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E163/5/1/13** កថាខណ្ឌ ៤០។

*សំអាងហេតុគ្រប់គ្រាន់ ដោយលើកឡើងពីអង្គហេតុជាក់ស្តែង ហើយចាំបាច់ត្រូវពន្យល់ពីអានុភាពរួមទៅលើបទចោទទាំងអស់ដែលបានបំបែកនោះ"*[16]។ អង្គជំនុំជម្រះតុលាការកំពូល ក៏បានបញ្ជាក់រួចមកហើយថា *"សេចក្តីសម្រេចស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវថ្លឹងថ្លែងតុល្យភាពរវាងផលប្រយោជន៍ផ្សេងៗរបស់ភាគី ដោយធ្វើការប្រៀបធៀបរវាងគុណសម្បត្តិ និងគុណវិបត្តិ នៃការជំនុំជម្រះក្តីតែមួយលើបទចោទទាំងអស់ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ធៀបនឹងការជំនុំជម្រះច្រើនវគ្គលើបទចោទដដែល"*[17]។

១៩. ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង មិនបានគោរពលក្ខខណ្ឌតម្រូវទូទៅនេះទាំងស្រុងនោះទេ ក្នុងសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ ហើយជាពិសេស មិនបានពិចារណាដល់លក្ខខណ្ឌតម្រូវទូទៅនេះ ក្នុងផ្នែកសំអាងហេតុរបស់ខ្លួននោះឡើយ។ ជាក់ស្តែង ទោះបីជានៅផ្នែកចុងក្រោយនេះ អង្គជំនុំជម្រះ បានពិនិត្យច្បាស់លាស់ជាងមុនទៅលើធាតុផ្សំដែលត្រូវយកចិត្តទុកដាក់ ដើម្បីសម្រេចអំពីឱកាសនៃការបំបែកកិច្ចដំណើរការនីតិវិធី ក៏អង្គជំនុំជម្រះសាលាដំបូង បានបកស្រាយខុសទៅលើលក្ខខណ្ឌតម្រូវដែលអង្គជំនុំជម្រះតុលាការកំពូលបានកំណត់ ហើយមិនបានទាញផលវិបាកចេញពីលក្ខខណ្ឌតម្រូវនោះឡើយ។

## II.ក. កំហុសក្នុងការពិចារណាអំពីញ្ញត្តិសិទ្ធិរបស់ជនជាប់ចោទ

### II.ក.១. សិទ្ធិក្នុងការទទួលបានភាពអាចព្យាករណ៍បាន និងសច្ចភាពគតិយុត្តិ

២០. ក្នុងកថាខណ្ឌ ២៤ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា ការបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី មិនប៉ះពាល់ដល់គោលការណ៍នៃភាពអាចព្យាករណ៍បាន

---

[16] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៣៦ ដែលដកស្រង់សេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E163/5/1/13** កថាខណ្ឌ ៣៥ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

[17] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៣៧ ដែលយោងលើសេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E163/5/1/13** កថាខណ្ឌ ៥០ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

និងសច្ចភាពគតិយុត្តិនោះទេ ដោយហេតុថាខ្លួនបានផ្ញើបញ្ជើកថាខណ្ឌពាក់ព័ន្ធ សម្រាប់សំណុំរឿង ០០២/០២ ដែលខ្លួនបានកំណត់វិសាលភាពរួចហើយ។ អង្គជំនុំជម្រះសាលាដំបូង ចាត់ទុកស្ថានភាពបច្ចុប្បន្នស្រដៀងគ្នានឹងស្ថានភាពដែលកើតមាន ក្នុងពេលបំបែកកិច្ចដំណើរការនីតិវិធីលើកមុនដែរ ហើយខ្លួនផ្អែកជាមូលដ្ឋានលើសេចក្តីសម្រេចមួយរបស់អង្គជំនុំជម្រះតុលាការកំពូល ដែលអះអាងថាកង្វល់របស់មេធាវីការពារក្តីមិនអាចយកជាការបានទេ ចាប់ពីពេលការបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានប្រកាសសាជាថ្មី រួចបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូល។ អង្គជំនុំជម្រះសាលាដំបូង បន្ថែមទៀតថា ភាគីមានឱកាសគ្រប់គ្រាន់ក្នុងការពិនិត្យភ័ស្តុតាងក្នុងសំណុំរឿង និងលើកឡើងនូវការជំទាស់ អនុលោមតាមវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះសាលាដំបូង *"យល់ឃើញថាការចេញសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ដែលកំណត់ច្បាស់អំពីវិសាលភាពនៃដំណាក់កាលបន្ទាប់នៃការជំនុំជម្រះក្តី ជាការជូនដំណឹងដល់ជនជាប់ចោទអំពីការចោទប្រកាន់នានាប្រឆាំងនឹងពួកគេ ហើយអនុញ្ញាតឲ្យពួកគេបានចូលរួមក្នុងការរៀបចំការការពារខ្លួន"*។ ទទ្បីករណ៍នេះរបស់អង្គជំនុំជម្រះសាលាដំបូង ខុសទាំងស្រុង។

## II.ក.១.១. ភាពមិនអាចព្យាករណ៍បាន និងអសច្ចភាពគតិយុត្តិពាក់ព័ន្ធនឹងបទចោទនាំមុខ

២១. នៅរៀងរាល់ពេលបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង មិនដែលកំណត់វិសាលភាពផ្សេង ក្រៅពីវិសាលភាពនៃដំណាក់កាលបន្ទាប់តែមួយវគ្គ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះតុលាការកំពូល បានរំឭកដល់អង្គជំនុំជម្រះសាលាដំបូងថា នៅពេលបំបែកកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូង ត្រូវកំណត់វិសាលភាពនៃដំណាក់កាលបន្តបន្ទាប់ទៀត ដោយផ្តល់ជា *"ផែនការច្បាស់លាស់ពាក់ព័ន្ធនឹងការជំនុំជម្រះក្តីវគ្គក្រោយ"* បន្តពីការជំនុំជម្រះក្តីដែលបានកំណត់វិសាលភាពរួចហើយ[18]។ ជាការពិត អង្គជំនុំជម្រះសាលាដំបូង បានទទួលបណ្តឹងឲ្យជំនុំជម្រះលើបទចោទទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមានកាតព្វកិច្ចជំនុំជម្រះឲ្យអស់បទចោទ[19] ហើយជនជាប់ចោទត្រូវដឹងថា តើខ្លួននឹងត្រូវជំនុំជម្រះលើបទចោទទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏យ៉ាងណា និងថាតើខ្លួននឹងត្រូវជំនុំជម្រះលើ

---

[18] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ២៤។

[19] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៦២ កំណត់សម្គាល់ជើងទំព័រ ១៧៦។

បទចោទទាំងអស់ តាមរបៀបណា។ ព័ត៌មានទាំងនេះ មានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការត្រៀមរៀបចំការពារខ្លួនជាទូទៅ ទាំងខាងសម្ភារៈ និងយុទ្ធសាស្ត្រ។ ដូច្នេះ ការកំណត់វិសាលភាពនៃដំណាក់កាលបន្ទាប់តែមួយវគ្គ ដោយទុកឲ្យដំណាក់កាលផ្សេងទៀតស្ថិតក្នុងភាពស្រពេចស្រពិល និងទុកទ្វារឲ្យនៅចំហដើម្បីទទួលយកគ្រប់លទ្ធភាពបែបនេះ មិនទាន់ជាការគោរពគោលការណ៍មូលដ្ឋានទាំងនេះនោះទេ ហើយរុញច្រានភាគីឲ្យធ្លាក់ទៅក្នុងអន្លង់នៃភាពមិនអាចព្យាករណ៍បាន និងអសច្ចភាពទាំងស្រុង។ អង្គជំនុំជម្រះតុលាការកំពូល បានរំឭកថា៖ *"អានុភាពនៃការបំបែកកិច្ចដំណើរការនីតិវិធី ត្រូវបានវាយតម្លៃ ទាក់ទិនទៅនឹងបទចោទទាំងមូលដែលបានកំណត់ មិនមែនគ្រាន់តែផ្នែកតូចមួយនោះឡើយ។ ដូច្នេះ នៅពេលចេញដីកាបំបែកកិច្ចដំណើរការនីតិវិធី លក្ខណៈទាំងស្រុងនៃបទចោទដែលដាក់បញ្ចូលនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានដោះស្រាយ ហើយពុំមាននីតិវិធីព្រហ្មទណ្ឌដែលចែងអំពីសិទ្ធិទទួលបានការជំនុំជម្រះបានឆាប់រហ័ស និងគោលការណ៍នៃប្រសិទ្ធភាព អនុញ្ញាតឲ្យទុកផ្នែកដែលត្រូវបានបំបែកចោលមិនដោះស្រាយនោះទេ"*[20]។

២២. ម្យ៉ាងវិញទៀត អង្គជំនុំជម្រះសាលាដំបូង បានបកស្រាយខុសនូវសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូល ទៅលើទឡ្ហីករណ៍របស់មេធាវីការពារក្ដី ក្នុងសំណុំរឿង ០០២/០១។ ជាក់ស្ដែង ពេលនោះ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចលើបញ្ហាឃុំខ្លួនលោក ខៀវ សំផន បណ្ដោះអាសន្ន ភ្ជាប់នឹងការចោទប្រកាន់ក្នុងសំណុំរឿង ០០២/០១។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ភាពអាចព្យាករណ៍បាន និងសច្ចភាពគតិយុត្តិ ត្រូវបានស្ដារឡើងវិញ ដោយសារតែការប្រកាសបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី និងការបញ្ជាក់ក្នុងបណ្ដឹងសាទុក្ខ ក៏ដោយ ក៏វាគឺជា *"ភាពអាចព្យាករណ៍បាន និងសច្ចភាពគតិយុត្តិ នៅពេលបញ្ចប់កិច្ចដំណើរការនីតិវិធី និងសាលក្រម ក្នុងសំណុំរឿង ០០២/០១"*[21]។ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ថា *"បញ្ហានៃការឃុំខ្លួនលោក ខៀវ សំផន ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ និងការ*

---

[20] សេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៤៣។

[21] សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ទៅលើសំណើសុំដោះលែងលោក ខៀវ សំផន ឲ្យនៅក្រៅឃុំជាបន្ទាន់ ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E275/2/3** ("សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការឃុំខ្លួន **E275/2/3**") កថាខណ្ឌ ៥២ (យើងខ្ញុំជាអ្នកគូសបន្ទាត់ពីក្រោម)។

*ជំនុំជម្រះក្ដីជាបន្តបន្ទាប់ទៀត ប្រសិនបើមាន នឹងតម្រូវឲ្យមានយុត្តិកម្ម និងការត្រួតពិនិត្យថ្មី"*[22]។ ជាក់ស្ដែង អង្គជំនុំជម្រះតុលាការកំពូល យល់ឃើញថា ភាពស្ងៀមស្ងាត់របស់អង្គជំនុំជម្រះសាលាដំបូង ចំពោះបទចោទដែលមិនត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០១ *"ធ្វើយុត្តិកម្មសម្រាប់ការបន្តឃុំខ្លួន លោកខៀវ សំផន កាន់តែមានតិចទៅៗ ទាក់ទងទៅនឹងបទចោទទាំងនោះ"*[23]។

២៣. ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង មិនអាចយកសេចក្ដីសន្និដ្ឋានរបស់អង្គជំនុំជម្រះតុលាការកំពូល មកប្រើប្រាស់ ហើយខ្លួនបែរជានៅស្ងៀមមិនអើពើលើជោគវាសនានៃបទចោទ ដែលមិនត្រូវបាន ដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០២ នោះទេ។ ទង្វើបែបនេះ គឺជាការប្រព្រឹត្តកំហុសអង្គច្បាប់ និងជាការរំលោភលើគោលការណ៍នៃភាពអាចព្យាករណ៍បាន និងសច្ចភាពគតិយុត្តិ។

## II.ក.១.២. <u>ភាពមិនអាចព្យាករណ៍បាន និងអសច្ចភាពគតិយុត្តិ ពាក់ព័ន្ធនឹងការកំណត់ឲ្យបានច្បាស់លាស់ពីវិសាលភាពនៃការជំនុំជម្រះក្ដី</u>

២៤. លើសពីនេះទៅទៀត មិនមែនដោយសារភាគីបានទទួលបញ្ជីកថាខណ្ឌនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងមានលទ្ធភាព (តែលើក្រដាស[24]) ពិនិត្យធាតុផ្សំភស្ដុតាង និងធ្វើការជំទាស់ បានន័យថា ភាគីត្រូវបានជូនដំណឹងអំពីវិសាលភាពច្បាស់លាស់នៃវគ្គជំនុំជម្រះក្ដីដំបូងទាំងពីរ ដែលកំណត់ដោយអង្គជំនុំជម្រះ នោះទេ។

២៥. ជាក់ស្ដែង បញ្ជីកថាខណ្ឌនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់សំណុំរឿង ០០២/០១ និងការផ្ដល់លទ្ធភាពធ្វើការជំទាស់លើធាតុផ្សំភស្ដុតាង មិនបានបញ្ចៀសបញ្ហាលំបាក និងសំណើសុំសេចក្ដីបំភ្លឺជាច្រើនអំពីសំណាក់ភាគី លើការបង្ហាញភស្ដុតាង និងការជ្រើសរើសឯកសារដែលត្រូវយកមកប្រើប្រាស់ និងពិចារណា សម្រាប់កំណត់បញ្ចូលទៅក្នុងប្រភេទសហឧក្រិដ្ឋកម្មរួម និង

[22] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការឃុំខ្លួន **E275/2/3** កថាខណ្ឌ ៥១។

[23] សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលលើការឃុំខ្លួន **E275/2/3** កថាខណ្ឌ ៤៩, សូមមើលផងដែរ សេចក្ដីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្ដីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៧២។

[24] សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E275/2/1/1** ("សំណើសុំបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម **E275/2/1/1**") កថាខណ្ឌ ៧៨-៩១។

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ម៉្យាងទៀត បញ្ហាទាំងនេះ នៅតែមិនទាន់បានដោះស្រាយនៅឡើយ[25]។

២៦. បន្ថែមលើនេះទៀត បញ្ជីកថាខណ្ឌនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះសម្រាប់សំណុំរឿង ០០២/០២ ដែលភ្ជាប់ជាមួយនឹងសេចក្ដីសម្រេចរងបណ្ដឹងសាទុក្ខនេះ បង្ហាញឲ្យឃើញថាបទពិសោធន៍លំបាកជួបប្រទះ កាលពីសំណុំរឿង ០០២/០១ នឹងកើតមានឡើងជាថ្មី ហើយនឹងប្រាកដជាលំបាកជាងមុន ដោយសារភាពច្រំដែលនៃការជំនុំជម្រះក្ដីទាំងពីរនេះ។ ជាក់ស្ដែង អង្គជំនុំជម្រះបានបញ្ចូលកថាខណ្ឌមួយចំនួនដែលមាននៅក្នុងវិសាលភាពសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿង០០២/០២ ដោយមូលហេតុថាបញ្ហាមួយចំនួន *"អាចមិនទាន់ត្រូវបានពិនិត្យ ដោយពេញលេញ នៅក្នុងការជំនុំជម្រះវគ្គមួយ (...) ពីព្រោះថាវិសាលភាពនៃវគ្គជំនុំជម្រះនេះមានកម្រិត ហើយបញ្ហាទាំងនេះ អាចមានភាពពាក់ព័ន្ធនៅក្នុងបរិបទនៃការជំនុំជម្រះសេចក្ដីវគ្គពីរដែរ។ អាស្រ័យហេតុនេះ ផ្នែកទាំងនេះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានបញ្ចូលយ៉ាងច្បាស់ក្រឡែតទៅក្នុងវិសាលភាពនៃការជំនុំជម្រះសេចក្ដីវគ្គពីរនេះ (...) ដោយហេតុថាផ្នែកទាំងនេះមានអង្គហេតុចោទប្រកាន់ពាក់ព័ន្ធនឹងសំណុំរឿង០០២/០២ ដែលមិនធ្លាប់ត្រូវបានពិនិត្យពីមុនទាំងស្រុង ឬ មិនត្រូវបានពិនិត្យពេញលេញ"*[26]។

២៧. ការអនុវត្តបែបនេះ នឹងបង្កឲ្យមានភាពច្របូកច្របល់ និង បញ្ហាលំបាក និងការយឺតយ៉ាវថែមទៀតក្នុងការដឹកនាំសវនាការ។

## II.ក.១.៣. ភាពមិនអាចព្យាករណ៍បាន និងអសច្ចភាពគតិយុត្តិទាក់ទងនឹងផលវិបាកនីតិវិធី ដែលកើតចេញពីការបំបែកកិច្ចដំណើរការនីតិវិធី

[25] សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤ ឯកសារ **E301/5/2** ("សេចក្ដីសន្និដ្ឋានពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ **E301/5/2**") កថាខណ្ឌ ៩-១២ និងសេចក្ដីយោងដែលបានដកស្រង់, សំណើសុំបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម **E275/2/1/1** និងសេចក្ដីបន្ថែម ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១៣ ឯកសារ **E275/2/1/3**។

[26] សេចក្ដីសម្រេចរងបណ្ដឹងសាទុក្ខ កថាខណ្ឌ ៤២។

២៨. ម្យ៉ាងវិញទៀត ដោយបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី និងដោយចេញសេចក្តីសម្រេចមួយចំនួនមិនសូវច្បាស់លាស់ និងចម្រូងចម្រាស អង្គជំនុំជម្រះរុញច្រានភាគីទៅក្នុងភាពមិនអាចព្យាករបាន និងអសច្ចភាពគតិយុត្តិ ពាក់ព័ន្ធនឹងក្របខណ្ឌនីតិវិធីនៃសំណុំរឿង ០០២ ទាំងមូលតែម្តង។

២៩. ជាក់ស្តែង អង្គជំនុំជម្រះ អះអាងថ្មីៗនេះថា វគ្គជំនុំជម្រះអង្គន់ដោយដីកាបំបែកកិច្ចដំណើរការនីតិវិធី មិនមែនជាសំណុំរឿងដាច់ដោយឡែកនោះទេ ប៉ុន្តែ ជា "វគ្គ" ឬ "ផ្នែក" ជាបន្តបន្ទាប់របស់សំណុំរឿងតែមួយ[27]។ ក៏ប៉ុន្តែ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះ បានចេញសេចក្តីសម្រេចផ្ទុយពីការអះអាងនេះ។ ភាពមិនស៊ីសង្វាក់គ្នានេះ ជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរទៅលើការដឹកនាំ និងការកំណត់ពេលវេលានីតិវិធី។

៣០. នៅកថាខណ្ឌ ២៣ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះពន្យល់ថា ដូចដែលខ្លួនបានបញ្ជាក់ *"តាំងពីពេលចាប់ផ្តើមបើកសវនាការ ការជំនុំជម្រះវគ្គមួយនេះ នឹងយកមកធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ការពិនិត្យពិស្តារបន្ថែមទៀតលើការចោទប្រកាន់នានា និងអង្គហេតុនៅសេសសល់ ដែលចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ក្នុងពេលជំនុំជម្រះវគ្គក្រោយៗ"*។ អង្គជំនុំជម្រះបានបន្ថែមថា *"ខ្លួនបានបញ្ជាក់ថា ធាតុផ្សំភស្តុតាងដែលត្រូវបានដាក់ឲ្យពិភាក្សាដេញដោលចំពោះមុខអង្គជំនុំជម្រះរួចហើយ នឹងត្រូវចាត់ទុកថាត្រូវបានដាក់ឲ្យពិភាក្សាដេញដោលចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង០០២/០២ ដែរ"*។ បើតាមអង្គជំនុំជម្រះ ការធ្វើបែបនេះ អាចធ្វើឲ្យយើងចៀសផុតពីភាពច្រំដែលនៃនីតិវិធី *"ដែលស៊ីពេលវេលាយ៉ាងវែង និងតម្រូវឲ្យចំណាយធនធានយ៉ាងច្រើន"* ក្នុងអំឡុងពេលជំនុំជម្រះវគ្គមួយ។

៣១. ក៏ប៉ុន្តែ ទោះបីជាអង្គជំនុំជម្រះពិតជាបានប្រកាសតាំងពីឆ្នាំ ២០១១ អំពីចេតនារបស់ខ្លួនក្នុងការយកការជំនុំជម្រះវគ្គមួយនេះជា "មូលដ្ឋានគ្រឹះទូទៅ" សម្រាប់វគ្គជំនុំជម្រះក្រោយៗទៀត ក៏ដោយក៏ខ្លួនមិនដែលបានពន្យល់ថា តើចេតនាចង់យកការជំនុំជម្រះវគ្គមួយជា "មូលដ្ឋានគ្រឹះទូទៅ" នេះមានន័យជាក់លាក់យ៉ាងដូចម្តេច ហើយក៏មិនដែលពន្យល់អំពីផលវិបាកនៃការអះអាងនេះលើនីតិ

---

[27] ការបញ្ជាក់បំភ្លឺទាក់ទងទៅនឹងការប្រើប្រាស់ភ័ស្តុតាង និងនីតិវិធីដើម្បីកោះហៅសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសាជាថ្មីឡើងវិញពីសំណុំរឿង ០០២/០១ សម្រាប់សំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **E302/5** ("អនុស្សរណៈ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ **E302/5**") កថាខណ្ឌ ៥។

វិធីដែរ (គឺមានតែការពន្យល់ថាសេចក្ដីសន្និដ្ឋានចោទប្រកាន់ និងសេចក្ដីសន្និដ្ឋានតបរបស់ភាគីត្រូវតែផ្ដោតទៅលើការចោទប្រកាន់ទាំងអស់ ដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះតែម្ដង)[28]។ គឺនៅខែ កុម្ភៈ ឆ្នាំ ១០១៤ នេះហើយទេ ដែលអង្គជំនុំជម្រះបានឆ្លើយតបនឹងសំណើរបស់សហព្រះរាជអាជ្ញា ថាធាតុផ្សំភស្តុតាងដែលត្រូវបានទទួលយកក្នុងការជំនុំជម្រះវគ្គមួយ នឹងយកមកប្រើជាមូលដ្ឋានគ្រឹះសម្រាប់វគ្គជំនុំជម្រះក្រោយៗទៀត ហើយតាមរយៈនេះ វាត្រូវបានទទួលយកដោយស្វ័យប្រវត្តិ នៅក្នុងសំណុំរឿង ០០២/០២ ដោយមិនចាំបាច់បញ្ជាក់បន្ថែមទៀតទេ[29]។ ក៏ប៉ុន្តែ នៅត្រង់កថាខណ្ឌ ៤៦ នៃសេចក្ដីសម្រេចរងបណ្ដឹងសាទុក្ខ អង្គជំនុំជម្រះបានបង្គាប់ភាគីឲ្យដាក់បញ្ជីឈ្មោះសាក្សី និងឯកសារ ដែលពួកគេចង់ឲ្យដាក់បញ្ចូលក្នុងសំណុំរឿង ០០២/០២ ។ ក៏ប៉ុន្តែ នៅក្នុងដីកាកំណត់កាលបរិច្ឆេទ និងរបៀបដាក់បញ្ជីទាំងនេះ អង្គជំនុំជម្រះបានបង្គាប់ឲ្យភាគីបញ្ចូលធាតុផ្សំភស្តុតាង ដែលខ្លួនបានទទួលរួចស្រេចទៅហើយនៅក្នុងការជំនុំជម្រះវគ្គ២នេះ[30] ។ ភាពច្រំដែលនៃនីតិវិធីនេះ ដែលស៊ីពេលវេលាយ៉ាងវែង និងតម្រូវឲ្យចំណាយធនធានយ៉ាងច្រើន ពិបាកយល់ និងស្រពេចស្រពិល ប្រសិនបើយើងត្រូវចាត់ទុកថាវគ្គជំនុំជម្រះដែលត្រូវបានបំបែក មិនមែនជាសំណុំរឿងដាច់ដោយឡែកពីគ្នា។

៣២. ភាពផ្ទុយគ្នារវាង "ការបន្តកិច្ចដំណើរការនីតិវិធី" [31] ជាវគ្គបន្តបន្ទាប់នៃសំណុំរឿងតែមួយ ដែលអង្គជំនុំជម្រះបានលើកឡើងថ្មីៗនេះ និងភាពច្រំដែលនៃដំណាក់កាលនីតិវិធី សម្រាប់សំណុំរឿងដាច់ដោយឡែកពីគ្នា[32] កាន់តែស្តែងឡើងយ៉ាងច្បាស់ទៅទៀត តាមរយៈការបង្គាប់ឲ្យភាគីដាក់បញ្ជីរួម

---

[28] ចម្លើយរបស់ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន ទៅនឹង "សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្ដីពីការប្រើប្រាស់ភស្តុតាង និងនីតិវិធីក្នុងការកោះហៅសាក្សីជាថ្មីពីសំណុំរឿង ០០២/០១ ទៅក្នុងសំណុំរឿង ០០២/០២" ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **E302/1** ("ចម្លើយ **E302/1**") កថាខណ្ឌ ២០-២២, សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ស្ដីពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមស្ថាពរនៃសំណុំរឿង ០០២/០១ មុននឹងចាប់ផ្ដើមសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **E301/5/5** ("សេចក្ដីសន្និដ្ឋានស្ដីពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមស្ថាពរ **E301/5/5**") កថាខណ្ឌ ៣៤-៣៦។

[29] អនុស្សរណៈ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ **E302/5** កថាខណ្ឌ ៧។

[30] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីរៀបចំសវនាការ ក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤ ឯកសារ **E305** ("ដីកា **E305**") កថាខណ្ឌ ១១ និងកំណត់សម្គាល់ជើងទំព័រ ១២។

[31] អនុស្សរណៈ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៤ **E302/5** កថាខណ្ឌ ៧។

[32] ចម្លើយ **E302/1** កថាខណ្ឌ ៦-១៧ និងកថាខណ្ឌ ៣០-៣២។

នៃអង្គហេតុព្រមព្រៀងគ្នា ស្របតាមវិធាន ៨០(៣)(ង) នៃវិធានផ្ទៃក្នុង[33]។ ភាពផ្ទុយគ្នានេះ កាន់តែជាក់ស្ដែងថែមទៀត តាមរយៈការគ្រោងរៀបចំសវនាការបឋម[34] ដែលជាកិច្ចបើកការជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង[35]។

៣៣. ការមិនបញ្ជាក់បំភ្លឺ និងមិនពន្យល់អំពីសញ្ញាណ "មូលដ្ឋានគ្រឹះទូទៅ" ដែលតាមរយៈសញ្ញាណនេះ អង្គជំនុំជម្រះផ្ដល់អំណះអំណាងពីភាពចាំបាច់នៃនីតិវិធីដ៏មានប្រសិទ្ធភាព និងឆាប់រហ័ស បង្កឲ្យមានព្យសនកម្ម ពីព្រោះសញ្ញាណនេះ មានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើការត្រៀមលក្ខណៈរបស់ភាគីការពារក្ដី។ ភាគីការពារក្ដី ត្រូវតែដឹងថាតើអង្គជំនុំជម្រះចង់ប្រើការជំនុំជម្រះវគ្គមួយ ជា"មូលដ្ឋានគ្រឹះទូទៅ" សម្រាប់វគ្គជំនុំជម្រះក្រោយៗទៀត តាមរបៀបណាដោយជាក់លាក់ ដើម្បីឲ្យខ្លួនអាចត្រៀមវគ្គជំនុំជម្រះទាំងនេះ ទៅតាមមូលដ្ឋានគ្រឹះនេះ។ ឥឡូវនេះ ភាគីការពារក្ដី មិនដឹងរឿងនេះសោះ។

៣៤. ម៉្យាងវិញទៀត បើតាមការយល់ឃើញរបស់ម្ចាស់បណ្ដឹងសាទុក្ខ សញ្ញាណ "មូលដ្ឋានគ្រឹះទូទៅ" នេះ ជាមូលហេតុដែលធ្វើឲ្យការជំនុំជម្រះវគ្គពីរ មិនអាចចាប់ផ្ដើមបាន មុនពេលចេញសាលក្រមស្ដាពរនៃការជំនុំជម្រះវគ្គមួយ[36]។ អង្គជំនុំជម្រះ បានបដិសេធភាពមិនអាចទៅរួចនេះ ក៏ប៉ុន្ដែ ខ្លួននៅស្ងៀមស្ងាត់មិនពន្យល់អំពីសញ្ញាណនេះ[37]។

---

[33] ដីកា **E305** កថាខណ្ឌ ៩។

[34] ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ ឯកសារ **E301/5** ("ផែនការការងារ **E301/5**") កថាខណ្ឌ ៨, សេចក្ដីសម្រេចរងបណ្ដឹងសាទុក្ខ កថាខណ្ឌ ៤៦, ដីកា **E305** កថាខណ្ឌ ១៥។

[35] វិធានផ្ទៃក្នុង វិធាន ៨០ ស្ទួន (១)៖ "ការជម្រះសេចក្ដីចាប់ផ្ដើមជាមួយនឹងសវនាការបឋម"។

[36] សេចក្ដីសន្និដ្ឋានស្ដីពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមស្ដាពរ **E301/5/5**, ប្រតិចារិកសវនាការ ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ឯកសារ **E1/239.1** ទំព័រ ២២ បន្ទាត់ ១១ ដល់ទំព័រ ២៦ បន្ទាត់ ២៥ (ចន្លោះម៉ោង [10.16.44] ដល់ម៉ោង [10.34.04])។

[37] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារពេលការចាប់ផ្ដើមសវនាការលើសំណុំរឿង ០០២/០២ រហូតដល់មានសាលក្រមស្ដាពរលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៤ ឯកសារ **E301/5/5/1** ("សេចក្ដីសម្រេចលើការរង់ចាំសាលក្រមស្ដាពរ **E301/5/5/1**")។

៣៥. ដោយមិនពន្យល់ឲ្យបានច្បាស់លាស់ និងទុកឲ្យមានភាពសម្រួចសម្រាស អង្គជំនុំជម្រះ ធ្វើឲ្យភាគីកាន់តែមិនមានភាពច្បាស់លាស់ខ្លាំងឡើងៗ ផ្នែកច្បាប់ និងនីតិវិធី។

## II.ក.២. សិទ្ធិទទួលបាននូវការជំនុំជម្រះដោយគ្មានការយឺតយ៉ាវហួសហេតុ

៣៦. នៅក្នុងសេចក្តីសម្រេចរងបណ្តឹងសាទុក្ខនេះ[38] អង្គជំនុំជម្រះ យល់ឃើញថាការបំបែកកិច្ចដំណើរការនីតិវិធីថ្មីនេះ មិនបណ្តាលឲ្យមានការយឺតយ៉ាវដោយគ្មានមូលហេតុ និងមិនប៉ះពាល់ដល់សិទ្ធិទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលសមស្របរបស់ជនជាប់ចោទឡើយ។ ក៏ប៉ុន្តែ មុននឹងឈានដល់ការចេញសេចក្តីសន្និដ្ឋានបែបនេះ អង្គជំនុំជម្រះ បកស្រាយខុសជាថ្មីទៀត នូវយុត្តិសាស្ត្ររបស់តុលាការកំពូល និងយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិពាក់ព័ន្ធ។ លើសពីនេះទៀត អង្គជំនុំជម្រះ បានគិតពិចារណាលើធាតុផ្សំមិនពាក់ព័ន្ធ និងយល់ច្រឡំអំពីអ្វីដែលត្រូវយកជាបទពិសោធពីសំណុំរឿង ០០២។

## II.ក.២.១. ការបកស្រាយយុត្តិសាស្ត្រខុស

៣៧. ជាបឋម ម្ចាស់បណ្តឹងសាទុក្ខ សូមកត់សម្គាល់ថាអង្គជំនុំជម្រះបានយល់ច្រឡំអំពីសេចក្តីសន្និដ្ឋាននានារបស់ខ្លួន[39]។ ផ្ទុយពីអ្វីដែលអង្គជំនុំជម្រះបានលើកឡើងនៅកថាខណ្ឌ ១៩ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខនេះ ម្ចាស់បណ្តឹងសាទុក្ខ មិនធ្លាប់បាននិយាយថាតុលាការកំពូលចាត់ទុកថាការបំបែកកិច្ចដំណើរការនីតិវិធី នឹងបណ្តាលឲ្យនីតិវិធីមានរយៈពេលវែងជាងនីតិវិធីនៃសំណុំរឿងតែមួយ ដោយចៀសមិនរួច នោះទេ។ តាមពិត ម្ចាស់បណ្តឹងសាទុក្ខ គ្រាន់តែដកស្រង់សម្តីរបស់តុលាការកំពូល ដែលបានរំលឹកអំពីធាតុផ្សំភស្តុតាង ដែលត្រូវបានយកមកគិតពិចារណាក្នុងយុត្តិសាស្ត្រ និងដែលបានកត់សម្គាល់ថាចៅក្រម (នៃតុលាការផ្សេងៗទៀត គឺមិនមែនចៅក្រមនៃតុលាការកំពូលទេ) ធ្លាប់បានយល់ឃើញថាវគ្គជំនុំជម្រះពីរបន្តបន្ទាប់គ្នា ត្រូវតែស៊ីពេលច្រើនជាងការជំនុំជម្រះរឿងក្តីតែមួយ ដោយចៀសមិនរួច[40]។

[38] សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ កថាខណ្ឌ ១៨-២៣។

[39] សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ កថាខណ្ឌ ១៩ និងកំណត់សម្គាល់ជើងទំព័រ ៥២។

[40] សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ **E301/5/2** កថាខណ្ឌ ៥ និងកថាខណ្ឌ ៦។

៣៨. នៅកថាខណ្ឌ ១៩ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះអះអាងថា *"យោងទៅតាមចំនួនអង្គហេតុដ៏ច្រើនលើសលប់ ដែលមានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំង ៧៧៩ ទំព័រ គ្មានអ្វីអាចកាត់បន្ថយរយៈពេលនីតិវិធីនៃសំណុំរឿង ០០២ នោះទេ"*។ វាប្រាកដណាស់។ ប៉ុន្តែ អង្គជំនុំជម្រះ មិនបានពិចារណាឲ្យបានច្បាស់លាស់ថាតើ បើធ្វើការជំនុំជម្រះជាវគ្គបន្តបន្ទាប់ រយៈពេលនីតិវិធីចាំបាច់សម្រាប់ពិនិត្យអ្វីដែលមានរៀបរាប់នៅក្នុង ៧៧៩ ទំព័រនេះ អាចវែងជាងរយៈពេលនីតិវធីនៃការជំនុំជម្រះរឿងក្តីតែមួយនោះទេ ហើយអង្គជំនុំជម្រះក៏មិនដែលធ្វើការប្រៀបធៀបរយៈពេលនីតិវិធីតាមការទាមទារនោះដែរ[41] (ចូរមើលក្នុងផ្នែក II.ខ)។

៣៩. ផ្ទុយទៅវិញ អង្គជំនុំជម្រះបែរជាបានត្រឹមតែបកស្រាយខុសនូវយុត្តិសាស្ត្រពីរដែលតុលាការកំពូលបានដកស្រង់ និងយល់ឃើញខុសថា *"មិនប្រាកដថាកង្វល់អំពីសិទ្ធិជនជាប់ចោទរបស់អង្គជំនុំជម្រះទាំងពីរ [...]*[42] *នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អាចយកមកអនុវត្តបានចំពោះការបំបែកកិច្ចដំណើរការនីតិវិធីជាយថាហេតុ នៅក្នុងសំណុំរឿង ០០២ នោះទេ"*[43]។

៤០. នៅកថាខណ្ឌ ២០ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះអះអាងថានៅក្នុងរឿងក្តី *Milosevic "អង្គជំនុំជម្រះតុលាការកំពូល បានយល់ឃើញថាការជំនុំជម្រះជាពីរវគ្គបន្តបន្ទាប់គ្នាទំនងជាពិបាកខ្លាំងណាស់ចំពោះ Milosevic ពីព្រោះគាត់ការពារក្តីដោយខ្លួនឯង"*។ ប៉ុន្តែ ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ មិនដូចនឹងករណី *Milosevic* ទេ។

៤១. ក៏ប៉ុន្តែនៅក្នុងសំណុំរឿង *Milosevic* អង្គជំនុំជម្រះតុលាការកំពូល បានធ្វើយុត្តិកម្មលើការច្របាច់រឿងក្តីបញ្ចូលគ្នា ដោយទទួលស្គាល់ថាវា *"ច្បាស់ណាស់"* ការជំនុំជម្រះរឿងក្តីរួមបញ្ចូលគ្នាមួយ

---

[41] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៣៧។

[42] បើតាមសំណៅជាភាសាបារាំង៖ "អង្គជំនុំជម្រះសាលាដំបូងទាំងពីររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី", បើតាមសំណៅជាភាសាអង់គ្លេស៖ "អង្គជំនុំជម្រះរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី"។

[43] សេចក្តីសម្រេចរងបណ្តឹងសាទុក្ខ កថាខណ្ឌ ២០។

*"ពិតជាទាមទារពេលវេលាវែង និងមានលក្ខណៈស្មុគស្មាញ"*[44]។ ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល មិនបានយកការលំបាកខ្លាំងរបស់ជនជាប់ចោទ ដោយសារគាត់គ្មានមេធាវី មកធ្វើជាមូលហេតុនៃការច្របាច់រឿងក្តីបញ្ចូលគ្នា នោះទេ។ ជាបឋម អង្គជំនុំជម្រះតុលាការកំពូល បានធ្វើការប្រៀបធៀប ជាលក្ខណៈទូទៅ អំពីការលំបាកនៃការជំនុំជម្រះរឿងក្តីច្របាច់បញ្ចូលគ្នាតែមួយ នឹងការលំបាកនៃការជំនុំជម្រះរឿងក្តីពីរបន្តបន្ទាប់គ្នា។ *"ការជំនុំជម្រះរឿងក្តីពីរបន្តបន្ទាប់គ្នានេះ ត្រូវការពេលវេលាវែងជាងការជំនុំជម្រះរឿងក្តីច្របាច់បញ្ចូលតែមួយ ដោយចៀសមិនរួច"*[45]។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ការជំនុំជម្រះក្តីនៅតែមានលក្ខណៈស្មុគស្មាញ ចំពោះករណីទាំងពីរ ពីព្រោះដំណើរការនីតិវិធីត្រូវការពេលវេលាវែង។ ភាគីលំបាកដូចគ្នា ប៉ុន្តែការជំនុំជម្រះរឿងក្តីច្របាច់បញ្ចូលតែមួយនេះ ត្រូវបានជ្រើសយក ដោយសារវាស៊ីពេលតិចជាង គឺមិនមែនដោយសារជនជាប់ចោទមិនមានមេធាវីនោះទេ៖

*"ដោយហេតុថាការចាំបាច់បានស្តែងឡើងក្នុងអំឡុងពេលជំនុំជម្រះរឿងក្តីទាំងពីរដែលបានប្រព្រឹត្តទៅជាយូរឆ្នាំនៅតុលាការ អង្គជំនុំជម្រះសាលាដំបូង នឹងត្រូវផ្អាកសវនាការម្តងម្កាល ដើម្បីឲ្យ<u>ភាគី</u>សម្រាកប្រមូលកម្លាំង និងតាមតម្រូវការ ដើម្បីឲ្យជនជាប់ចោទដែលមិនត្រូវការជំនួយការពីមេធាវីមានពេលសម្រាក ដោយហេតុថាការងារការពារក្តីខ្លួនមានទំហំធំធេង។ ការសម្រេចចិត្តរបស់ជនជាប់ចោទក្នុងការមិនយកមេធាវីការពារក្តី មិនត្រូវយកមកប្រើប្រឆាំងនឹងតុលាការទេ"*[46]។

៤២. ម្យ៉ាងទៀត វាមិនមែនឥតប្រយោជន៍នោះទេក្នុងការបញ្ជាក់ថា ក្នុងរឿងក្តីនេះ អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចជ្រើសរើសយកការច្របាច់រឿងក្តីបញ្ចូលគ្នា ដែលបណ្តាលឲ្យការជំនុំជម្រះក្តីមានរយៈពេលវែង និងមានលក្ខណៈស្មុគស្មាញ ដោយបាននិយាយសង្កត់ទៅលើទំនួលខុសត្រូវធ្ងន់របស់រាជអាជ្ញា ក្នុងការធ្វើយ៉ាងណាចៀសវាងកុំដាក់បន្ទុកការងារធ្ងន់ហួសហេតុពេកលើអង្គជំនុំជម្រះ ក៏ដូចជាទៅលើភាគីការពារក្តី ក្នុងការធ្វើយ៉ាងណាកុំឲ្យដាក់ឯកសារឥតប្រយោជន៍គ្មានភាពពាក់ព័ន្ធ និងទៅលើករណីយកិច្ចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការធានាឲ្យបាននូវការជំនុំ

---

[44] រដ្ឋអាជ្ញា តទល់នឹង *Slobodan Milosevic* រឿងក្តីលេខ IT-99-37-AR73, IT-01-50-AR73 និង IT-01-51-AR73 សំអាងហេតុនៃសេចក្តីសម្រេចលើបណ្តឹងបន្ទាន់បន្ទំរបស់រដ្ឋអាជ្ញាប្រឆាំងនឹងការបដិសេធពាក្យសុំបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ("សេចក្តីសម្រេច *Milosevic*") កថាខណ្ឌ ២៥។

[45] សេចក្តីសម្រេច *Milosevic* កថាខណ្ឌ ២៧។

[46] សេចក្តីសម្រេច *Milosevic* កថាខណ្ឌ ២៧។

ជម្រះមួយដែលអាចគ្រប់គ្រងបានតាមតែអាចធ្វើទៅបាន តាមរយៈសិទ្ធិអំណាចដែលបានផ្តល់ជូនដោយវិធានផ្ទៃក្នុង[47]។

៤៣. នៅកថាខណ្ឌ ២១ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខនេះ អង្គជំនុំជម្រះលើកឡើងថា នៅក្នុងរឿងក្តី *Mladic* អង្គជំនុំជម្រះសាលាដំបូង បានយល់ឃើញថាការបំបែកកិច្ចដំណើរការនីតិវិធី និងការដឹកនាំសវនាការនៃការជំនុំជម្រះក្តីទាំងពីរ បង្កព្យសនកម្មដល់ជនជាប់ចោទ ពីព្រោះការដែលគិតគូរអំពីបញ្ហារៀបចំសវនាការ ក្នុងរឿងក្តីមួយ ក្នុងពេលតែមួយ ជាមួយនឹងការចូលរួមក្នុងការជំនុំជម្រះនៅសាលាដំបូង ឬតុលាការកំពូលក្នុងរឿងក្តីមួយទៀត អាចធ្វើឲ្យបន្ទុកការងារធ្ងន់ធ្ងរហួសកម្លាំង។ អង្គជំនុំជម្រះបានបន្ថែមថា ចៅក្រមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី យល់ឃើញថាការចាំបាច់ក្នុងការសម្របសម្រួលមេធាវីការពារក្តីពីរក្រុម ដើម្បីតំណាងឲ្យជនជាប់ចោទតែមួយ កាន់តែធ្វើឲ្យការត្រៀមលក្ខណៈការពារក្តីកាន់តែលំបាកទៅទៀត។ បើតាមអង្គជំនុំជម្រះ ការពិចារណាបែបនេះ មិនអាចយកមកអនុវត្តក្នុងសំណុំរឿង ០០២ បានទេ ពីព្រោះ *"បញ្ហាមុនពេលជំនុំជម្រះជាច្រើនត្រូវបានសម្រេចរួចហើយ"* ហើយលើសពីនេះទៅទៀត ជនជាប់ចោទទាំងអស់សុទ្ធតែតំណាងដោយមេធាវីតែមួយក្រុម។ ដូច្នេះ មិនត្រូវការសម្របសម្រួលមេធាវីពីរក្រុមដាច់ពីគ្នានោះទេ។

៤៤. ផ្ទុយទៅវិញ អង្គជំនុំជម្រះសាលាដំបូង បានខកខានក្នុងការបង្ហាញថា ក្នុងរឿងក្តី *Mladic* ចៅក្រមរបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី យល់ឃើញជាពិសេសថា៖ *"ការចែករំលែកពេលវេលា និងការយកចិត្តទុកដាក់ដែលចាំបាច់សម្រាប់ជនជាប់ចោទ ក្នុងការចូលរួមការការពារខ្លួនក្នុងសំណុំរឿងទាំងពីរ ធ្វើឲ្យការចូលរួមរបស់គាត់មិនសូវមានប្រសិទ្ធិភាព ហើយអាចបណ្តាលឲ្យមានភាពយឺតយ៉ាវលើកិច្ចដំណើរការនីតិវិធី សម្រាប់ការជំនុំជម្រះទាំងពីរផងដែរ"*[48]។ សច្ចភាពនេះ ពិតជាត្រឹមត្រូវក្នុងករណីដំណើរការនីតិវិធីជាច្រើនក្នុងពេលតែមួយ ទោះបីជាដំណើរការនីតិវិធីទាំងនោះប្រព្រឹត្តទៅបែបណាក៏ដោយ ហើយសច្ចភាពនេះរឹតតែសមស្របនៅក្នុង

---

[47] សេចក្តីសម្រេច *Milosevic* កថាខណ្ឌ ២៥-២៦។

[48] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Ratko Mladic* សំណុំរឿងលេខ IT-09-92-PT សេចក្តីសម្រេចលើសារណារួមរបស់រដ្ឋអាជ្ញា ក្នុងការបំបែកកិច្ចដំណើរការនីតិវិធីរបស់ដីការបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីធ្វើការជំនុំជម្រះដាច់ពីគ្នា និងដើម្បីធ្វើវិសោធនកម្មលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១១ ("សេចក្តីសម្រេចក្នុងរឿងក្តី *Mladic*") កថាខណ្ឌ ៣១។

សំណុំរឿង ០០២ ដោយហេតុថាជនជាប់ចោទទាំងពីររូប ម្នាក់មានអាយុ ៨៣ ឆ្នាំ និងម្នាក់ទៀតមានអាយុ ៨៧ ឆ្នាំ។ ម្យ៉ាងវិញទៀត ទោះបីជាបញ្ហាមួយចំនួនមុនការចាប់ផ្តើមការជំនុំជម្រះ ត្រូវបានសម្រេចក៏ដោយក្តី ក៏បញ្ហានៅមិនទាន់បានដោះស្រាយទាំងអស់នោះដែរ ហើយការត្រៀមរៀបចំសំណុំរឿង ០០២/០២ នាពេលបច្ចុប្បន្ន ជាមួយនឹងដំណាក់កាលនីតិវិធីតម្រូវដោយអង្គជំនុំជម្រះសាលាដំបូង ស្តែងឲ្យឃើញថាដំណាក់កាលត្រៀមរៀបចំនេះពុំមែនជារយៈពេលដែលគ្មានសកម្មភាពនោះឡើយ។ ចំណុចចុងក្រោយ គឺថាសច្ចភាពនេះ នៅតែសមស្របក្នុងក្របខ័ណ្ឌនៃការការពារខ្លួន ដែលធានាដោយមេធាវីតែមួយក្រុម។ គ្មានមនុស្សណាម្នាក់ អាចបែងចែកខ្លួនជាពីរបាននោះទេ។ ការចូលរួមក្នុងដំណើរការនីតិវិធីច្រើនក្នុងពេលតែមួយ បើទោះបីជាដំណើរការនីតិវិធីនោះប្រព្រឹត្តទៅបែបណាក៏ដោយ នឹងតម្រូវឲ្យមានការបែងចែកការងារផ្ទៃក្នុងជាក់ជាពុំខាន។ ដូច្នេះ ជនជាប់ចោទ អាចត្រូវការសម្របសម្រួលក្រុមការងារការពារក្តីរបស់ខ្លួនជាពីរផ្នែក ដែលត្រូវធ្វើការលើនីតិវិធីខុសៗគ្នា ប៉ុន្តែក្នុងពេលតែមួយ។

៤៥. នៅកថាខណ្ឌ ២២ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធជាថ្មី (ដោយពុំបានយោងលើកមក) នូវទឡ្ហីករណ៍របស់ចៅក្រមក្នុងសំណុំរឿង *Mladic* ដែលបានលើកឡើងថា៖ *"ក្នុងករណីដែលដំណើរការប្តឹងសាទុក្ខមានរយៈពេលវែង ការពន្យារពេលដែលអាចកើតមានសម្រាប់ការជំនុំជម្រះទីពីរ នឹងកាន់តែប្រាកដប្រជា"*[49]។ អង្គជំនុំជម្រះសាលាដំបូង *"ពុំយល់ឃើញថា ការបំបែកកិច្ចដំណើរការនីតិវិធីដែលនៅសេសសល់ អាចនឹងបង្កើតឲ្យមានរយៈពេលពុំសមស្រប ក្រោមមូលហេតុថាការបំបែកកិច្ចដំណើរការនីតិវិធីនេះ អាចនឹងតម្រូវឲ្យលើកពេលការជំនុំជម្រះទីពីរ ដើម្បីទុកពេលវេលាចាំបាច់ដល់ជនជាប់ចោទ ក្នុងការត្រៀមរៀបចំការការពារខ្លួន"*។ អង្គជំនុំជម្រះសាលាដំបូង គូសបញ្ជាក់ថាមេធាវីការពារក្តីត្រូវបានតែងតាំងនៅឆ្នាំ ២០០៧ ហើយបានចូលរួមក្នុងដំណើរនីតិវិធីតាំងពីដំណាក់កាលស៊ើបអង្កេត ដែលខុសគ្នាពីនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាក្រុមមេធាវីការពារក្តីនីមួយៗមានពេលវេលាគ្រប់គ្រាន់ និងធនធានសម្រាប់ត្រៀមរៀបចំការងាររបស់ខ្លួន ប្រឈមនឹងការចោទប្រកាន់ទាំងឡាយ ដែលមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

[49] សេចក្តីសម្រេចក្នុងរឿងក្តី *Mladic*" កថាខណ្ឌ ៣២។

៤៦. ការធ្វើការប្រៀបធៀបជាមួយមេធាវីនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី មិនត្រឹមត្រូវនោះទេ ព្រោះថាបើទោះបីជាមេធាវីទាំងអស់នោះ មិនបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីតាំងពីពេលស៊ើបអង្កេតក៏ដោយ នោះគឺដោយសារតែវាគ្មានការស៊ើបអង្កេតនៅក្នុងនីតិវិធីចោទប្រកាន់របស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី។ មេធាវីទាំងអស់នោះ ត្រូវបានតែងតាំង និងបានត្រៀមរៀបចំការការពារក្តីរបស់ខ្លួន រយៈពេលជាច្រើនឆ្នាំមុននឹងសវនាការជំនុំជម្រះក្តីចាប់ផ្តើម ហើយម្យ៉ាងវិញទៀត ពួកគេគឺជាអ្នកដឹកនាំការស៊ើបអង្កេតដោយខ្លួនឯងផ្ទាល់តែម្តង។ បន្ទាប់មក ម្ចាស់បណ្តឹងសាទុក្ខសូមរំឭកថា មេធាវីសព្វថ្ងៃរបស់ខ្លួនពុំបានមានវត្តមានក្នុងដំណាក់កាលស៊ើបអង្កេតឡើយនោះទេ ហើយមេធាវីម្នាក់ក្នុងចំណោមមេធាវីរបស់គាត់ ទើបតែត្រូវបានតែងតាំងនៅខែ វិច្ឆិកា ឆ្នាំ ២០១១[50] ប៉ុណ្ណោះ ពោលគឺនៅពេលចាប់ផ្តើមបើកសវនាការពិភាក្សាលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០១។

៤៧. ជាពិសេសទៅទៀតនោះ អង្គជំនុំជម្រះសាលាដំបូង បានធ្វើឱ្យស្រពេចស្រពិលនូវភាពសាំញ៉ាំនៃដំណាក់កាលប្តឹងសាទុក្ខ (ហើយដែលបច្ចុប្បន្ននេះ បានក្លាយជាដំណាក់កាលប្តឹងសាទុក្ខផ្សេងៗគ្នា) ក្នុងសំណុំរឿង ០០២ ក៏ដូចជាភាពសាំញ៉ាំនៃបញ្ហាគតិយុត្ត និងនីតិវិធីដែលកើតចេញមកជាពិសេសពីសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់ខ្លួន ដែលមួយផ្នែកមួយនៃបញ្ហាទាំងអស់នោះមានលក្ខណៈចម្លែក ហើយដែលគ្មានភាគីណាមួយបានត្រៀមរៀបចំខ្លួនសម្រាប់បញ្ហាទាំងអស់នោះក្នុងដំណាក់កាលស៊ើបអង្កេតឡើយ។ សូមរំឭកថា វិធាន ៨៩ ស្ទួនពីរ ដែលអនុញ្ញាតឱ្យមានការបំបែកកិច្ចដំណើរការនីតិវិធី ទើបតែត្រូវបានបញ្ចូលទៅក្នុងវិធានផ្ទៃក្នុង នៅខែ កុម្ភៈ ឆ្នាំ ២០១១ ប៉ុណ្ណោះ ពោលគឺបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងទទួលជំនុំជម្រះសំណុំរឿង ០០២។ ការបកស្រាយ និងការអនុវត្តវិធាននេះ បានក្លាយជាកម្មវត្ថុនៃការប្តឹងសាទុក្ខជាច្រើនលើកច្រើនសា ហើយដែលករណីនេះនៅតែបន្តកើតមាននាពេលបច្ចុប្បន្ន។ ម្យ៉ាងវិញទៀត នីតិវិធីចម្រុះដែលបង្កើតនៅ អ.វ.ត.ក គឺមានតែមួយគត់ ហើយអន្តរាគមន៍របស់អង្គជំនុំជម្រះតុលាការកំពូល ក៏ពុំសូវមានដោយមូលហេតុថា មានសេចក្តីសម្រេចតិចតួចបំផុត ដែលបើកផ្លូវឱ្យប្តឹងសាទុក្ខភ្លាមៗ។

[50] លោកមេធាវី គង់ សំអុន ត្រូវបានតែងតាំងនៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ លោកមេធាវី Arthur VERCKEN ត្រូវបានតែងតាំងនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ហើយលោកស្រីមេធាវី Anta GUISSÉ ត្រូវបានតែងតាំងនៅថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២។

៤៨. ដូច្នេះ យុត្តិសាស្ត្រក្នុងរឿងក្តី *Milosevic* និង *Mladic* ដែលអង្គជំនុំជម្រះតុលាការកំពូលបានយោងទៅលើ គឺពិតជាពាក់ព័ន្ធ និងអាចអនុវត្តបានសម្រាប់សំណុំរឿង ០០២។ យុត្តិសាស្ត្រក្នុងរឿងក្តីទាំងពីរនេះ ត្រូវបានគាំទ្រដោយយុត្តិសាស្ត្រផ្សេងៗទៀតរបស់អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (សូមមើលខាងក្រោម ចំណុច II. ខ) ហើយអង្គជំនុំជម្រះសាលាដំបូង ទំនងជាបានអនុវត្តតាមយុត្តិសាស្ត្រទាំងអស់នោះ ដើម្បីពិចារណាពីឱកាសនៃការបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី ក្នុងសំណុំរឿង ០០២។ ដោយពុំបានអនុវត្តបែបនេះ និងដោយពុំបានប្រៀបធៀបទាល់តែសោះ ពីរយៈពេលនៃការជំនុំជម្រះក្តីតែមួយ ទៅនឹងរយៈពេលនៃការជំនុំជម្រះក្តីច្រើន លើបទចោទប្រកាន់ដូចគ្នា មុននឹងពិចារណាថាការបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី នឹងមិននាំឲ្យមានការពន្យារពេលណាមួយនោះ អង្គជំនុះជម្រះសាលាដំបូង បានប្រព្រឹត្តកំហុសលើអង្គច្បាប់ ដែលបានធ្វើឲ្យសេចក្តីសម្រេចរបស់ខ្លួនមានភាពមិនត្រឹមត្រូវ។

## II. ក.២.២. កំហុសក្នុងការពិចារណាបទពិសោធន៍ក្នុងសំណុំរឿង ០០២

៤៩. នៅកថាខណ្ឌ ២៣ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង បានអះអាងទាំងភាន់ច្រឡំថា *"ទឡ្ហីករណ៍ដែលថាការបំបែកកិច្ចដំណើរការនីតិវិធី អាចនឹងបណ្តាលឲ្យមានការពន្យារពេលហួសហេតុនោះ គឺពុំត្រឹមត្រូវឡើយឆ្លងតាមបទពិសោធន៍នៃសំណុំរឿង ០០២"*។ ប៉ុន្តែទឡ្ហីករណ៍របស់ខ្លួននេះ គឺពិតជាខុស ព្រោះថាអង្គជំនុំជម្រះសាលាដំបូង បានខកខានពិចារណាលើធាតុផ្សំដែលមានភាពពាក់ព័ន្ធជាងគេ។

៥០. មូលហេតុគឺថា អង្គជំនុំជម្រះសាលាដំបូង បានត្រឹមតែបង្ហាញថាភ័ស្តុតាងទាំងឡាយដែលត្រូវបានពិភាក្សាដេញដោលនៅចំពោះមុខខ្លួនក្នុងសំណុំរឿង ០០២/០១ ត្រូវបានចាត់ទុកថាត្រូវបានពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២ ដូចគ្នា។ ដូចដែលយើងបានឃើញពីខាងដើមរួចមកហើយថា (ចំណុច II.ក.១.៣) ការធ្វើបែបនេះ ក៏ពុំបានរាំងស្ទះដល់ការកៀងគរពេលវេលា និងធនធានពីភាគីទាំងអស់ និងភាពច្រំដែលនៃដំណាក់កាលនីតិវិធីផ្សេងៗទៀតនោះដែរ។

៥១. អង្គជំនុំជម្រះសាលាដំបូង ក៏បានត្រឹមតែអះអាងថាបុគ្គលមួយចំនួនដែលសក្ខីកម្មរបស់ពួកគេទំនង ជាពាក់ព័ន្ធនឹងសំណុំរឿង ០០២ ទាំងមូល ត្រូវបានស្តាប់ចម្លើយក្នុងវគ្គទីមួយនៃការជំនុំជម្រះ ដែល នេះអាចនឹងជួយកាត់បន្ថយតម្រូវការកោះហៅសាក្សីមួយចំនួនសាជាថ្មីទៀត សម្រាប់ការជំនុំជម្រះ ក្រោយៗទៀត។ ដូចដែលយើងនឹងឃើញក្នុងផ្នែកខាងក្រោម (សូមមើលចំណុច II.គ) ការកាត់ បន្ថយតម្រូវការកោះហៅសាក្សីមួយចំនួននេះ ត្រូវបានវាយតម្លៃខ្ពស់ជ្រុលហួសហេតុដោយអង្គជំនុំ ជម្រះសាលាដំបូង។

៥២. អង្គជំនុំជម្រះសាលាដំបូង មិនដែលបានពិចារណាពីពេលវេលាបន្ថែម ដែលកើតឡើងដោយចៀស មិនផុតពីការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ហើយផ្ទុយទៅវិញ បើផ្អែងតាមបទពិសោធន៍ក្នុង សំណុំរឿង ០០២ ពេលវេលានេះអាចព្យាករណ៍បានយ៉ាងងាយ។ ជាបឋម គឺពេលវេលាជាច្រើន ប្រើសម្រាប់ការតទល់គ្នាក្នុងដំណើរការនីតិវិធីជាលាយលក្ខណ៍អក្សរ និងផ្ទាល់មាត់ ដែលកើត ចេញមកពីសេចក្តីសម្រេចទាំងពីរដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី ក្នុងនោះមានរួមទាំង ការតទល់ក្នុងពេលបង្ហាញភស្តុតាងផងដែរ[51]។ បន្ទាប់មក គឺភាពច្រំដែលនៃដំណាក់កាលរៀបចំ សម្រាប់ការជំនុំជម្រះនីមួយៗ (សូមមើលចំណុច II.ក.១.៣)។ ភាពច្រំដែលនេះ ក៏នឹងមានផងដែរ នៅដំណាក់កាលបិទបញ្ចប់នៃការជំនុំជម្រះនីមួយៗ ដែលមានជាអាទិ៍ សេចក្តីសន្និដ្ឋានបញ្ចប់កិច្ច ពិភាក្សាដេញដោលរបស់ភាគី សេចក្តីសន្និដ្ឋានការពារចុងក្រោយ ការប្រជុំពិភាក្សាសម្រេច និងការ សរសេរសាលក្រម និងដំណាក់កាលប្តឹងសាទុក្ខ។

៥៣. កំហុសឆ្គងដែលអង្គជំនុំជម្រះសាលាដំបូងបានប្រព្រឹត្តនៅក្នុងការគ្រប់គ្រង និងប្រសិទ្ធិភាពនៃ ដំណើរការនីតិវិធី ត្រូវបូកផ្សំជាមួយនឹងកំហុសធ្ងន់ធ្ងរជាច្រើនផ្សេងទៀត ដែលអង្គជំនុំជម្រះ សាលាដំបូងបានប្រព្រឹត្ត នៅក្នុងការពិចារណាលើព្យសនកម្មមកលើសិទ្ធិ របស់ជនជាប់ចោទ។

---

[51] សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ **E301/5/2** កថាខណ្ឌ ៩ ដល់កថាខណ្ឌ ១០, សំណើសុំបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម **E275/2/1/1** និង *Addendum* ឯកសារ **275/2/1/3,** បណ្តឹងសាទុក្ខភ្លាមៗ[របស់មេធាវីការពារក្តីលោក នួន ជា] ជំទាស់នឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី និងសារណាតបចំពោះបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាជំទាស់នឹងសេចក្តីសម្រេចលើកទីពីរលើការបំបែកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E284/4/1** កថាខណ្ឌ ១២, កថាខណ្ឌ ១៤ និង កថាខណ្ឌ ១៨ ដល់កថាខណ្ឌ ២០។

## II.ខ. កំហុសក្នុងការយកចិត្តទុកដាក់លើប្រសិទ្ធិភាព និងការគ្រប់គ្រងដំណើរការនីតិវិធី

៥៤. នៅកថាខណ្ឌ ៣០ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ បន្ទាប់ពីបានយោងទៅកថាខណ្ឌ ២៦ និងកថាខណ្ឌ ២៧ និងក្រោយពីបានគណនាចំនួនសាក្សីដែលត្រូវស្តាប់ចម្លើយ និងចំនួនកថាខណ្ឌនៃដីកាដំណោះបញ្ជូនរឿងទៅជំនុំជម្រះដែលខ្លួនកំពុងទទួលជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថាការបំបែកកិច្ចដំណើរការនីតិវិធីសាជាថ្មី គឺស្ថិតនៅលើផ្លូវនៃការជំនុំជម្រះដោយយុត្តិធម៌។ ជាថ្មីម្តងទៀត ការធ្វើសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូងបែបនេះ គឺខុសឆ្គងទាំងស្រុង ព្រោះថាវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង មានការភាន់ច្រឡំ។

៥៥. សរុបមក ក្នុងកថាខណ្ឌ ២៦ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា ការស្តាប់ចម្លើយសាក្សី ៩៦ រូប ក្នុងវគ្គទីពីរនៃការជំនុំជម្រះ គឺ ងាយស្រួលគ្រប់គ្រងជាងការស្តាប់ចម្លើយសាក្សីទាំងអស់ ដែលបានស្នើឡើងដោយភាគីទាំងអស់សម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ដោយដកចេញអ្នកដែលបានផ្តល់សក្ខីកម្មរួចហើយក្នុងវគ្គទីមួយនៃការជំនុំជម្រះ។ ការកាត់បន្ថយនេះ បាននាំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសន្និដ្ឋានថា *"ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងត្រូវពិនិត្យសំណុំរឿង ០០២ ទាំងមូលនោះ អង្គជំនុំជម្រះត្រូវកោះហៅសាក្សីច្រើនជាងមុន"*។ នៅក្នុងកថាខណ្ឌ ២៧ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាការលើកយកកថាខណ្ឌនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយចំនួនតិចមកពិនិត្យ ពិតជាងាយស្រួលគ្រប់គ្រងជាងការលើកយកទាំង ១១៤៧ កថាខណ្ឌ ដែលនៅសល់ត្រូវជំនុំជម្រះ។

៥៦. ដូច្នេះ ទឡ្ហីករណ៍របស់អង្គជំនុំជម្រះសាលាដំបូង គឺមានបំណងអះអាងថាចំនួនតិចប្រសើរជាងចំនួនច្រើន...។ វាជាការពិតណាស់ដែលថាការគ្រប់គ្រងតែផ្នែកណាមួយនៃរឿងក្តី គឺតែងតែងាយស្រួលគ្រប់គ្រងរឿងក្តីទាំងមូល។ ប៉ុន្តែសំណួរដែលចោទឡើងនោះគឺថា តើការគ្រប់គ្រងរឿងក្តីទាំងមូលដោយភាគីទាំងអស់ជាច្រើនដង ពិតជាងាយស្រួលជាង និងមានប្រសិទ្ធិភាពជាងការគ្រប់គ្រងរឿងក្តីទាំងមូលតែមួយលើក ឬក៏យ៉ាងណា។

៥៧. យ៉ាងណាមិញ អធិបញ្ញារបស់អង្គជំនុំជម្រះតុលាការកំពូល ដែលផ្អែកលើយុត្តិសាស្ត្រអន្តរជាតិ ពិតជាច្បាស់លាស់ណាស់ត្រង់ចំណុចនេះ និងលើវិធីសាស្ត្រដែលត្រូវប្រកាន់យកដោយអង្គជំនុំជម្រះ

សាលាដំបូង ដែលបានពិចារណាដល់ការបំបែកកិច្ចដំណើរការនីតិវិធី។ ការគណនាត្រូវធ្វើឡើងដោយប្រៀបធៀប *"[...] ការជំនុំជម្រះតែមួយលើបទចោទទាំងអស់ដែលមានក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលខុសប្លែកពីផលប្រយោជន៍ និងគុណវិបត្តិនៃការបើកការជំនុំជម្រះច្រើនលើបទចោទដូចៗគ្នា"*[52]។ ហើយបើទោះបីជាចៅក្រមនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ បានពិចារណាឃើញថា *"សវនាការពីរបន្តបន្ទាប់គ្នា [...] ពិតជាត្រូវការចំណាយពេលវេលាច្រើនជាងសវនាការតែមួយ ដោយចៀសមិនរួចឡើយ"*[53] នោះក៏ព្រោះតែចៅក្រមទាំងអស់នោះបានធ្វើការប្រៀបធៀបបែបនេះ។

៥៨. វិធីសាស្ត្រនេះ ត្រូវបានអនុវត្តតែនៅក្នុងរឿងក្តី *Milosevic* និង *Mladic* ដូចដែលយើងបានឃើញពីខាងដើមតែប៉ុណ្ណោះ (ចំណុច II.ក.២.១) ដើម្បីឈានទៅដល់ការធ្វើសេចក្តីសន្និដ្ឋានជាប្រយោជន៍ដល់ការជំនុំជម្រះបញ្ចូលគ្នាតែមួយ។ ជាក់ស្តែង ក្នុងរឿងក្តី *Gotovina និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានទទួលស្គាល់ទឡ្ហីករណ៍របស់អង្គជំនុំជម្រះសាលាដំបូងដែលបានយល់ឃើញថា *"ជាការពិត ទោះបីជាការជំនុំជម្រះជនជាប់ចោទតែមួយរូប អាចនឹងមានរយៈពេលខ្លីជាងការជំនុំជម្រះតែមួយលើជនជាប់ចោទទាំងអស់គ្នាក៏ដោយ ក៏ផ្ទុយទៅវិញការជំនុំជម្រះតែមួយលើជនជាប់ចោទទាំងបីរួមគ្នា មានរយៈពេលខ្លីជាងការជំនុំជម្រះពីរ ឬបីដាច់ពីគ្នា"*[54]។ អង្គជំនុំជម្រះតុលាការកំពូលបានបន្ថែមទៀតថា *"ការជំនុំជម្រះពីរដាច់គ្នា ទោះជាការជំនុំជម្រះនោះប្រព្រឹត្តទៅក្នុងពេលតែមួយ ឬក៏យ៉ាងណាក៏ដោយ ប្រហែលជាទាមទារម៉ោងធ្វើសវនាការ និងនីតិវិធីច្រើនជាង និងមធ្យោបាយតុលាការច្រើនជាងការជំនុំជម្រះរួមគ្នា។ ម្យ៉ាងវិញទៀត ការជំនុំជម្រះពីរដាច់គ្នា ប្រហែលជានឹងអាចនាំឱ្យមានភាពមិនស៊ីសង្វាក់គ្នា"*[55]។

---

[52] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៣៧។

[53] សេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះតុលាការកំពូល ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី **E284/4/8** កថាខណ្ឌ ៣៨។

[54] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Gotovina *និងអ្នកផ្សេងទៀត* សំណុំរឿង IT-01-45-AR73.1, IT-03-73-AR73.1 & IT-03-73-AR73.2 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអនុញ្ញាតឱ្យកែប្រែបទចោទប្រកាន់ និងការជំនុំជម្រះរឿងក្តីច្របាច់បញ្ចូលតែមួយ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចក្នុងរឿងក្តី *Gotovina និងអ្នកផ្សេងទៀត*") កថាខណ្ឌ ៤៣។

[55] សេចក្តីសម្រេចក្នុងរឿងក្តី *Gotovina និងអ្នកផ្សេងទៀត* កថាខណ្ឌ ៤៤។

៥៩. ក្នុងរឿងក្តី *Pandurevic និងអ្នកផ្សេងទៀត* និងរឿងក្តី *Tolimir និងអ្នកផ្សេងទៀត* អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានគាំទ្រទទ្ធីករណ៍របស់ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ដែលបានច្របាច់បញ្ចូលនីតិវិធី ដោយអង្គជំនុំជម្រះតុលាការកំពូលបានពិចារណាឃើញថា ប្រសិនបើរឿងក្តីនីមួយៗត្រូវជំនុំជម្រះដាច់ចេញពីគ្នា ការជំនុំជម្រះទាំងអស់អាចនឹងមានរយៈពេលពី ៩៣ ទៅ ៩៥ ខែ ខណៈដែលការជំនុំជម្រះរួមគ្នាអាចនឹងមានរយៈពេលត្រឹមតែពី ១៨ ទៅ ២៤ ខែ[56]ប៉ុណ្ណោះ។ ផ្តើមចេញពីចំណុចខាងលើនេះ ការពន្យាររយៈពេលពី ៤ ទៅ ១០ ខែ សម្រាប់ការជំនុំជម្រះតែមួយ ដែលទំនងជាអាចមានរយៈពេល ១៤ ខែ ត្រូវបានចាត់ទុកថាសមស្របទៅនឹងប្រយោជន៍នៃប្រសិទ្ធិភាពយុត្តិធម៌[57]។

៦០. ជាក់ស្តែង អង្គជំនុំជម្រះសាលាដំបូង ពុំបានព្យាយាមពិចារណា ឬក៏ប្រៀបធៀបរយៈពេលនៃការបន្តគ្នានៃការជំនុំជម្រះដាច់ៗគ្នាជាច្រើន ធៀបទៅនឹងរយៈពេលនៃការជំនុំជម្រះដែលមានតែមួយ។ ប្រសិនបើខ្លួនបានធ្វើការងារនេះនោះ អង្គជំនុំជម្រះសាលាដំបូង ទំនងជានឹងអាចធ្វើសេចក្តីសន្និដ្ឋានបានយ៉ាងត្រឹមត្រូវលើរយៈពេល និងប្រសិទ្ធិភាពនៃដំណើរការនីតិវិធី ហើយគឺវាទំនងជាងក្នុងការពិនិត្យអង្គហេតុ និងបទចោទប្រកាន់ទាំងមូល តាមរយៈការជំនុំជម្រះក្តីតែមួយ ដែលអង្គជំនុំជម្រះសាលាដំបូងនៅកំពុងជំនុំជម្រះ។ សេចក្តីសន្និដ្ឋាននេះ ទំនងជាអាចត្រូវបានគាំទ្រដោយបញ្ហាកោះហៅសាក្សីមកសាជាថ្មី។

## II.គ. <u>កំហុសក្នុងការពិចារណាលើគុណវិបត្តិដោយថាហេតុ ដែលអាចកើតមានលើសាក្សី</u>

[56] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Pandurevic និងអ្នកផ្សេងទៀត* សំណុំរឿង IT-05-86-AR73.1 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ *Vinko Pandurevic* ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការច្របាច់ជនជាប់ចោទបញ្ចូលគ្នា ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចក្នុងរឿងក្តី *Pandurevic និងអ្នកផ្សេងទៀត*") កថាខណ្ឌ ២០, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Tolimir និងអ្នកផ្សេងទៀត* សំណុំរឿង IT-04-80-AR73.1 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ *Radivoje Miletic* ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការច្របាច់ជនជាប់ចោទបញ្ចូលគ្នា ចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០៦ ("សេចក្តីសម្រេចក្នុងរឿងក្តី *Tolimir និងអ្នកផ្សេងទៀត*") កថាខណ្ឌ ២៦។

[57] សេចក្តីសម្រេចក្នុងរឿងក្តី *Pandurevic និងអ្នកផ្សេងទៀត*' កថាខណ្ឌ ២១, សេចក្តីសម្រេចក្នុងរឿងក្តី *Tolimir និងអ្នកផ្សេងទៀត* កថាខណ្ឌ ២៦។

៦១. នៅក្នុងកថាខណ្ឌ ២៣ នៃសេចក្តីសម្រេចរងបណ្តឹងសាទុក្ខ អង្គជំនុំជម្រះសាលាដំបូង អះអាងថា ដោយហេតុថាក្នុងរឿងក្តី ០០២/០១ ខ្លួនបានស្តាប់ចម្លើយបុគ្គលមួយចំនួន ដែលសក្ខីកម្មរបស់ពួកគេទំនងជាពាក់ព័ន្ធសម្រាប់សំណុំរឿង ០០២ ទាំងមូល អង្គជំនុំជម្រះសាលាដំបូង *"បានកាត់បន្ថយនូវសេចក្តីត្រូវការចាំបាច់សម្រាប់សាក្សីមួយចំនួន ដែលត្រូវកោះហៅសាជាថ្មីក្នុងដំណាក់កាលបន្តបន្ទាប់នៃសំណុំរឿង ០០២"* បើទោះបីជាខ្លួននឹងពិនិត្យស្ថានភាពជាក់ស្តែងទៅតាមករណីនីមួយៗ។ ក្នុងកថាខណ្ឌ ២៨ នៃសេចក្តីសម្រេចដដែលនេះដែរ អង្គជំនុំជម្រះសាលាដំបូង បានបន្ថែមថា "*ទោះបីជាវិសាលភាពនៃកិច្ចដំណើរការនីតិវិធីបន្តបន្ទាប់មិនទាន់បានកំណត់ក៏ដោយ ក៏អង្គជំនុំជម្រះពិចារណាថា បុគ្គលដែលនឹងត្រូវកោះហៅសាជាថ្មី បន្ទាប់ពីបានបង្ហាញខ្លួនក្នុងសំណុំរឿង ០០២/០២ នឹងមានចំនួនតិចតួចប៉ុណ្ណោះ*" ហើយថា"*ការយោងទៅលើវិធានផ្ទៃក្នុង អាចចៀសវាងការបង្ហាញភស្តុតាងច្រំដែល ឬមិនពាក់ព័ន្ធ ហើយវាថែមទាំងអាចសម្រាលដល់បុគ្គលពាក់ព័ន្ធ*"។

៦២. អង្គជំនុំជម្រះសាលាដំបូង មើលស្រាលពីភាពចាំបាច់ក្នុងការកោះហៅសាជាថ្មី នូវសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលកើតចេញមកពីការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ហើយនិងរយៈពេលនៃការកោះហៅសាជាថ្មីនេះ និងការរំខានដល់បុគ្គលទាំងអស់នោះ។

៦៣. ជាបឋម ទឡ្ហីករណ៍ដែលថាការយោងទៅលើវិធានផ្ទៃក្នុង អាចចៀសវាងនូវការបង្ហាញភស្តុតាងមិនពាក់ព័ន្ធ ឬច្រំដែលនោះ គឺពិតជាមិនត្រឹមត្រូវឡើយ ព្រោះថាការជំនុំជម្រះដាច់ៗពីគ្នា ត្រូវបានសន្មតថាត្រូវផ្តោតលើការពិនិត្យអង្គហេតុផ្សេងៗគ្នា។

៦៤. បន្ទាប់មក បទពិសោធន៍ក្នុងការជំនុំជម្រះរឿងក្តី ០០២/០១ គឺច្បាស់លាស់ណាស់។ ហេតុផលគឺថា មានមនុស្សតែប្រាំនាក់ប៉ុណ្ណោះ ដែលត្រូវបានស្តាប់ចម្លើយក្នុងអំឡុងពេលនៃការជំនុំជម្រះរឿងក្តីនេះ លើអង្គហេតុទាំងមូលនៃសំណុំរឿង ០០២[58]។ ផ្អែកតាមមូលហេតុដែលបានលើកឡើងនៅក្នុងសារណាមុនៗ ជាទ្រឹស្តី ទោះបីជាអ្នកជំនាញទាំងពីររូបដែលបានផ្តល់សក្ខីកម្មរួចហើយ អាចត្រូវបានស្តាប់ចម្លើយក្នុងសំណុំរឿង ០០២ ទាំងមូលក៏ដោយ ក៏ករណីនេះពុំបានកើតឡើងក្នុងការអនុវត្ត

[58] សាក្សី ឡុង នរិន្ទ ហៅ រិទ្ធិ (TCW-395), សាក្សី ស គឹមល្អុត ហៅ ម៉ី (TCW-583), សាក្សី សៅ សារុន (TCW-604), សាក្សី យុន គីម ហៅ ខាំ (TCW-797) និងសាក្សី ខៀវ នៅ (TCW-321)។

ជាក់ស្តែងឡើយ[59]។ ជាក់ស្តែង លោក CHANDLER ពុំបានផ្តល់សក្ខីកម្មលម្អិតលើមន្ទីរ ស-២១ នៅក្នុងសំណុំរឿង ០០២/០១ នោះទេ[60]។ មន្ទីរ ស-២១ ស្ថិតក្នុងការពិនិត្យក្នុងសំណុំរឿង ០០២/០២ ដូច្នេះ លោក CHANDLER គួរតែត្រូវបានកោះហៅមកសាជាថ្មី។ ជាក់ស្តែង លោក SHORT ពុំបានផ្តល់សក្ខីកម្មលើបញ្ហាអំពើប្រល័យពូជសាសន៍ ក្នុងពេលជំនុំជម្រះសំណុំរឿង ០០២/០១ នោះទេ[61]។ អំពើប្រល័យពូជសាសន៍ ស្ថិតក្នុងការពិនិត្យក្នុងសំណុំរឿង ០០២/០២ ដូច្នេះ លោក SHORT គួរតែត្រូវបានកោះហៅមកសាជាថ្មី។

៦៥. ម្យ៉ាងវិញទៀត ក្នុងចំណោមបុគ្គលផ្សេងទៀតដែលត្រូវបានស្តាប់ចម្លើយ ហើយដែលសក្ខីកម្មរបស់

[59] ចម្លើយ **E302/1** កថាខណ្ឌ ២៣ និងកំណត់សម្គាល់ជើងទំព័រលេខ ២៣, កថាខណ្ឌ ២៤ និងកំណត់សម្គាល់ជើងទំព័រលេខ ២៥, សំណើសុំបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម **E275/2/1/1** កថាខណ្ឌ ៦៣ ដល់កថាខណ្ឌ ៦៥, បណ្តឹងសាទុក្ខភ្លាមៗរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចចេញតាមរយៈអ៊ីម៉ែលរបស់លោកស្រី Susan LAMB នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ឯកសារ **E264/1/2/1** កថាខណ្ឌ ៣៨ ដល់កថាខណ្ឌ ៤៦ និងកថាខណ្ឌ ៥០, បណ្តឹងសាទុក្ខជាបន្ទាន់របស់លោក ខៀវ សំផន ប្រឆាំងនឹងសេចក្តីសម្រេចតាមរយៈអ៊ីម៉ែលរបស់អ្នកស្រី LAMB នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១៣ - សារណាបន្ថែម ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៣ ឯកសារ **E264/1/2/1/1** កថាខណ្ឌ ១៧។

[60] លោកស្រីចៅក្រម CARTWRIGHT ប្រតិចារឹកសវនាការ ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E1/91.1** ទំព័រ ១៧ បន្ទាត់ ៦ ដល់ទំព័រ ១៨ បន្ទាត់ ៤ (ចន្លោះម៉ោង [09.49.42] ដល់ម៉ោង [09.54.53]), លោក ABDULHAK តំណាងសហព្រះរាជអាជ្ញា ប្រតិចារឹកសវនាការ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E1/92.1** ទំព័រ ៨៤ បន្ទាត់ ១ ដល់បន្ទាត់ ៩ (ចន្លោះម៉ោង [15.31.18] ដល់ម៉ោង [15.34.13]), ទំព័រ ៨៤ បន្ទាត់ ២៤ ដល់បន្ទាត់ ២៥ (ចន្លោះម៉ោង [15.34.13] ដល់ម៉ោង [15.36.05]), លោកស្រីចៅក្រម CARTWRIGHT ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E1/93.1** ទំព័រ ៣ បន្ទាត់ ១៤ ដល់ទំព័រ ៤ បន្ទាត់ ១១ (ចន្លោះម៉ោង [09.08.42] ដល់ម៉ោង [09.12.26]), លោក ABDULHAK តំណាងសហព្រះរាជអាជ្ញា ប្រតិចារឹកសវនាការ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E1/93.1** ទំព័រ ៦ បន្ទាត់ ៣ ដល់បន្ទាត់ ៥ (ចន្លោះម៉ោង [09.14.50] ដល់ម៉ោង [09.16.28]), លោកចៅក្រម LAVERGNE ប្រតិចារឹកសវនាការ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០១២ ឯកសារ **E1/94.1** ទំព័រ ៨២ បន្ទាត់ ១២ ដល់បន្ទាត់ ១៥ (ចន្លោះម៉ោង [15.01.51] ដល់ម៉ោង [15.03.03])។

[61] ចម្លើយតបទៅនឹងសំណើតាមវិធាន ៨៧(៤) សុំដាក់ឯកសារថ្មីទៅក្នុងសំណុំរឿង ពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី លោក François PONCHAUD និងលោក Sydney SCHANBERG (E243) ព្រមទាំងអ្នកជំនាញ លោក Philip SHORT (E226, E226/1 និង E230) និងលោកស្រី Elizabeth BECKER (E232 និង E232/1) ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៣ ឯកសារ **E260** កថាខណ្ឌ ៧ និងកថាខណ្ឌ ៨, ប្រតិចារឹកសវនាការ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០១៣ ឯកសារ **E1/189.1** ទំព័រ ៤៦ បន្ទាត់ ២៣ ដល់ទំព័រ ៤៧ បន្ទាត់ ១ (ចន្លោះម៉ោង [11.52.38] ដល់ម៉ោង [11.54.36])។

ពួកគេពាក់ព័ន្ធនឹងអង្គហេតុផ្សេងៗទៀតនៃសំណុំរឿង ០០២ គឺអ្នកទាំងអស់នោះពុំបានផ្តល់សក្ខីកម្ម ក្រៅដែនកំណត់នៃវិសាលភាពសំណុំរឿង ០០២/០១ នោះឡើយ[62]។ ដូច្នេះ សក្ខីកម្មពួកគេនៅក្នុង ការជំនុំជម្រះក្រោយៗមកទៀត នឹងមិនត្រូវអាចមិនពាក់ព័ន្ធ ឬច្រំដែលបានជាដាច់ខាត។ ម្យ៉ាងវិញ ទៀត ក៏មិនអាចថាមិនកោះហៅអ្នកទាំងនោះមកសាជាថ្មីសម្រាប់ការជំនុំជម្រះមួយ ឬច្រើន ក្រោយៗទៀត ដែលវិសាលភាពនៃការជំនុំជម្រះនោះនៅមិនទាន់ត្រូវបានបញ្ជាក់នៅឡើយ (ហើយដែលការកោះហៅបុគ្គលទាំងនោះ គឺអាស្រ័យលើការកំណត់វិសាលភាពនៃការជំនុំជម្រះ ដូចជាអ្វីដែលអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់បានប្រកាស)។

## III. សេចក្តីសន្និដ្ឋាន

៦៦. កំហុសជាច្រើនដែលអង្គជំនុំជម្រះបានប្រព្រឹត្តទៅលើអង្គច្បាប់ បានបង្កឲ្យមានកំហុសយ៉ាងជាក់ស្តែងចេញពីការប្រើឆន្ទានុសិទ្ធិ ដែលបង្កឲ្យមានព្យសនកម្មទៅលើម្ចាស់បណ្តឹងសាទុក្ខ។ ដូច្នេះ ការបំបែកកិច្ចដំណើរការនីតិវិធីថ្មីដែលសម្រេចដោយអង្គជំនុំជម្រះនេះ បង្កឲ្យមានអតុល្យភាពយ៉ាងខ្លាំងរវាងសិទ្ធិនៃភាគី។ ការបំបែកកិច្ចដំណើរការនីតិវិធីនេះ រំលោភទៅលើសិទ្ធិនៃភាពអាចព្យាករណ៍បាន និងសច្ចភាពគតិយុត្តិ របស់ លោក ខៀវ សំផន ហើយដូចគ្នានេះដែរ ក៏រំលោភទៅលើសិទ្ធិរបស់លោកក្នុងការទទួលបានការជំនុំជម្រះក្នុងចិរវេលាមួយសមរម្យ និងសិទ្ធិទទួលបានការបង្កភាពងាយស្រួលក្នុងការរៀបចំការការពារក្តី។ ភាពស្រពិចស្រពិលនៃការដាក់អង្គហេតុបញ្ចូលក្នុងសំណុំរឿង ០០២/០២ ដូចដែលអង្គជំនុំជម្រះបានធ្វើនេះជាឧទាហរណ៍ជាក់ស្តែងមួយ។

៦៧. ក្នុងនាមអង្គជំនុំជម្រះដែលជាអ្នកគ្រប់គ្រងសំណុំរឿង និងជាអ្នករក្សាសិទ្ធិនៃការការពារក្តី អង្គជំនុំជម្រះគួរតែ ប្រៀបធៀបរវាងគុណសម្បត្តិ និងគុណវិបត្តិនៃការជំនុំជម្រះក្តីតែមួយ ធៀបនឹងការជំនុំជម្រះក្តីច្រើនវគ្គ ដូចដែលតុលាការកំពូលបានណែនាំ។ អង្គជំនុំជម្រះក៏គួរតែគ្រោងទុកមុនផងដែរ នូវរាល់លទ្ធភាពទាំងឡាយដែលមាន (ហើយដោយសារអង្គជំនុំជម្រះមានអំណាចច្រើន) ដើម្បីព្យាយាមរៀបចំជំនុំជម្រះចុងក្រោយតែមួយគត់នៅក្នុងសំណុំរឿង ០០២ ដោយកែលម្អការគ្រប់គ្រង និងប្រសិទ្ធភាពនៃនីតិវិធី ដោយប្រើប្រាស់មធ្យោបាយផ្សេងទៀត ក្រៅពីការបំបែកនីតិវិធីថ្មី។

[62] ចម្លើយ **E302/1** កថាខណ្ឌ ២២។

៦៨. គេតែងតែសង្កេតឃើញថា អង្គជំនុំជម្រះបានគេចចេញពីការងារវិភាគនេះ ហើយការបំបែកកិច្ចដំណើរការនីតិវិធីថ្មីនេះមិនមែនជាប្រយោជន៍សម្រាប់យុត្តិធម៌ឡើយ។ ដូច្នេះ ត្រូវធ្វើមោឃភាពលើសេចក្តីសម្រេចដែលរងបណ្តឹងសាទុក្ខនេះ។

៦៩. **អាស្រ័យហេតុនេះ** សូមអង្គជំនុំជម្រះតុលាការកំពូលមេត្តា ៖

- ប្រកាសទទួលយកបណ្តឹងសាទុក្ខនេះ
- ធ្វើមោឃភាពលើសេចក្តីសម្រេចដែលរងបណ្តឹងសាទុក្ខនេះ។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ<br><br>មេធាវី Arthur VERCKEN | រាជធានីភ្នំពេញ<br><br>ប៉ារីស<br><br>ប៉ារីស | |
| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |